# ជំពូក ១១

# អរិយធម៌ខ្មែរនៅសម័យក្រោយអង្គរ

## (សម័យភ្នំពេញ ចតុមុខ សម័យលង្វែក សម័យឧដុង្គ ស្រីសន្ធរ)

តាមទស្សនៈថ្មី គេបានចាត់ទុកថា **ប្រវត្តិសាស្ត្រ** ជាធម៌សំយោគរវាង **វប្បធម៌** និង **សង្គមធម៌** ហើយពុំមែនជាកំរងព្រឹត្តិការណ៍នយោបាយដែលបានកើតឡើងជាបន្តបន្ទាប់គ្នាហូរហែតែប៉ុណ្ណោះទេ ។ យើងយល់ថាទស្សនៈនេះមានលក្ខណៈសមរម្យណាស់ ហើយយើងចង់យកមកអនុវត្តក្នុងកិច្ចការរបស់យើងនេះដែរ ដើម្បីបង្ហាញអោយអ្នកអានឃើញភាពនៃសង្គមខ្មែរយើងក្នុងសម័យកាលនិមួយៗ ។ ប៉ុន្តែ ក្នុងការធ្វើអោយសំរេចបំណងរបស់យើងខាងលើនេះ យើងត្រូវជួបប្រទះនឹងឧបសគ្គជាច្រើន ។ យ៉ាងណាមិញ ឯកសារដែលយើងប្រើប្រាស់សំរាប់ចងក្រងប្រវត្តិសាស្ត្រខ្មែរសម័យក្រោយអង្គរនេះ ច្រើនតែជា **រាជពង្សាវតារ** ។ ដូចមិត្តអ្នកអានបានជ្រាបស្រាប់ហើយថា **រាជពង្សាវតារ** ជាឯកសារអធិប្បាយអំពីដំណើរប្រែប្រួលរបស់វង្សស្តេចផែនដី ម្ល៉ោះហើយពត៌មានដែលយើងអាចស្រង់ចេញពីឯកសារប្រភេទនេះច្រើនតែសង្កត់ទៅលើរឿងរ៉ាវដែលទាក់ទងនឹងព្រះមហាក្សត្ររាជ្យវង្សានុវង្ស នាម៉ឺន ចំបាំង ចំណែកឯពត៌មានដែលទាក់ទងនឹងជីវភាពប្រជារាស្ត្រ ការរស់នៅ និងមែកធាងឯទៀតនៃ **វប្បធម៌** និង **សង្គមធម៌** មានតិចតួចស្តួចស្តើងណាស់ ។ តាមការសង្កេត សៀវភៅប្រវត្តិសាស្ត្រជាភាសាជាតិក្តី ជាភាសាបរទេសក្តី ដែលបានចងក្រងរួចមកហើយរហូតដល់ពេលនេះក៏ពុំអាចទៅដល់គោលដៅខាងលើនេះដែរ ។ ចំពោះយើងវិញ យើងពុំហ៊ានអះអាងថានឹងទៅដល់គោលដៅទាំងស្រុងនោះដែរ តែទោះបីមានកង្វះឯកសារយ៉ាងណាក៏ដោយ ក៏យើងនឹងខិតខំសាកល្បងដោយប្រើឯកសារដែលមានរួចមកហើយ ផ្សំជាមួយនឹងឯកសារបរទេសខ្លះដើម្បីធ្វើអោយសង្គមខ្មែរក្នុងអតីតកាលលេចរូបរាងឡើងចំពោះមុខអ្នកអានតាមលទ្ធភាពដែលយើងអាចធ្វើបាន ។

# ក. នយោបាយ

## ១. របបនយោបាយ

### ១.១. ព្រះរាជា ៖ ជីវភាព និងអំណាច

ទោះបីលទ្ធិទេវរាជត្រូវខ្មែរបោះបង់ចោលជាស្ថាពរតាំងពីបដិវត្តន៍ នាយត្រសក់ផ្អែមមកម្ល៉េះក៏ដោយ ក៏ព្រះមហាក្សត្រនៅមានលក្ខណៈពិសិដ្ឋពុំមានជនណាល្មើសបានឡើយ ហើយដែលគេនិយមហៅថា **ព្រះសម្មតិទេព** គឺថាជាជនខ្ពង់ខ្ពស់ផុតគេឬក៏ជា **ទេវតា** ដោយសន្មតក្នុងចំណោមមនុស្ស ជាអាណាប្រជានុរាស្ត្ររបស់ព្រះអង្គ ។

លក្ខណៈពិសិដ្ឋរបស់ព្រះមហាក្សត្រខាងលើនេះ គឺបានមកពីពិធី **រាជាភិសេក** អោយឡើង **សោយរាជសម្បត្តិ** (manger la royauté) ។ ពាក្យ **សោយ** នេះខ្មែរពីបុរាណលោកបានប្រើជាហូរហែរៀងមក មានភស្តុតាងក្នុងសិលាចារឹកជាដើម តែលោកសរសេរថា **ស្វេយ** ទៅវិញ (ស្វេយរជ្យ៖ ធម្មិរាជ្យ - សិលាចារឹកប្រាសាទ លុះគ.ស. ១០៤៩) ។ គួរគប្បីជ្រាបថាក្សត្រអង្គណាដែលមិនទាន់បានអភិសេក ហើយគ្រាន់តែបានទទួលរាជសម្បត្តិគ្រប់គ្រងអាណាប្រជានុរាស្ត្រជាបណ្ដោះអាសន្នសិននោះ តាមក្បួនលោកអោយហៅថា **គ្រងរាជសម្បត្តិ** ដូចជាករណីរបស់ **ព្រះបរមរាជាទី២ ចៅពញា យ៉ាត** កាលដែលវាយរំដោះបានរាជធានីអង្គរពីកណ្ដាប់ដៃនៃទ័ពសៀម និង**ព្រះចន្ទរាជា** កាលដែលមិនទាន់ច្បាំងឈ្នះ **ស្ដេចកន** ជាស្ថាពរនៅឡើយ ។ ម្យ៉ាងទៀត ប្រសិនបើអភិសេកក្នុងពេលធ្វើសង្គ្រាមលោកអោយហៅថា **សង្គ្រាមាភិសេក** ហើយប្រសិនបើអភិសេកក្រោយដែលបានបង្ក្រាប ខ្មាំងសត្រូវអោយរាបទាបលោកអោយហៅថា **ឲ្រាឆ្កាភិសេក** ទៅវិញ ។

ត្រង់នេះ គួរគប្បីជ្រាបថាក្សត្រដែលអាចអភិសេកឡើងសោយរាជ្យពេញលក្ខណៈជាព្រះមហាក្សត្របានលុះណាតែមាន **គ្រឿងសំរាប់រាជ្យ** គឺ **ព្រះខាន់រាជ្យ១ ព្រះលំពែងជ័យ ១** និង **គ្រឿងព្រះបញ្ចក្សត្រ** ។ ប៉ុន្តែ បើតាមឯកសារខ្មែរខ្លះ (21) គេបញ្ចូល**ព្រះខាន់រាជ្យ** ឬ **ព្រះខាន់ជ័យ** នេះទៅក្នុងចំណោម**គ្រឿងបញ្ចក្សត្រ** វិញដែលគេហៅថា **បញ្ចកកុធភ័ណ្ឌ** ឬ **រាជកកុធភ័ណ្ឌ** គឺ ៖

១. ព្រះមកុដ

២. ព្រះវាលវីជនី (ផ្លិតធ្វើដោយរោមសត្វពណ៌ស)

៣. ព្រះខាន់

៤. ស្វេតច្ឆត្រ

៥. ព្រះសុវណ្ណបាទុកា (ស្បែកជើងមាស)

ប្រភពដដែលបាននិយាយទៀតថា : " កាលនឹងស្តេចចេញទៅធ្វើរាជសង្គ្រាមក៏ត្រូវយក **ព្រះខាន់** ជាប់នឹងព្រះអង្គទៅផងជាដរាប តែមិនមែនយកទៅប្រើកាប់សម្លាប់ផ្តេសផ្តាសដូចអាវុធឯ ទៀតទេ លុះតែកាលណាសត្រូវដែលអង់អាចចូលមកដល់ព្រះអង្គ ដែលត្រូវប្រើអាវុធខ្លីប្រហារនោះ ទោះនឹងយក **ព្រះខាន់** ប្រហារអោយវិនាសទៅបាន រួមសេចក្តីទៅថាត្រូវតែសម្លាប់ដោយកិត្តិយស " ។

ទោះបីចាប់ពីរជ្ជកាលព្រះបាទត្រសក់ផ្អែមតមក ខ្មែរយើងកាន់ខ្ជាប់តែព្រះពុទ្ធសាសនាហីនយានក៏ដោយ តែ **ព្រះខាន់រាជ្យ** និង **គ្រឿងបញ្ចក្សេត្រ** ត្រូវបានពួក**បាគូ** ជាអ្នកថែរក្សាយ៉ាងតឹងរ៉ឹង ហើយនឹងមានកិច្ចធ្វើពិធីបូជាជារៀងរាល់ខែផង ។ ពួកបាគូនេះជាកូនចៅមានតំណវង្សពីពួកព្រាហ្មណ៍បុរោហិត គឺពួកព្រាហ្មណ៍ដែលមាននាទីប្រារព្ធធ្វើរាជពិធីផ្សេងៗ ក្នុងព្រះរាជវាំងនាសម័យអង្គរ ដែលព្រះរាជាខ្មែរភាគច្រើននិយមរាប់អានសាសនាព្រាហ្មណ៍ជាងព្រះពុទ្ធសាសនា ។

តាមរាជពង្សាវតារខ្មែរ ថាកាលដែល**ស្តេចកន** មានជ័យជំនះហើយ **សម្តេចឥសីតន្ទ** បានយក **ព្រះខាន់រាជ្យ ព្រះលំពែងជ័យ** និង **គ្រឿងបញ្ចក្សេត្រ** ទៅលាក់ទុកក្នុងរន្ធនៃប្រហោងដើមចំបក់មួយនៅក្នុងព្រៃ ។ លុះស្តេចកនទទួលអភិសេកឡើងសោយរាជ្យ ព្រះអង្គទ្រង់ចាត់អោយគេ ដើររក **គ្រឿងសំរាប់រាជ្យ** ទាំងនោះនៅគ្រប់ទិសទីតែរកពុំឃើញសោះ ។ ចំណែកឯព្រះ **ចន្ទរាជា** កាលដែលនាម៉ឺនសព្វមុខមន្ត្រីសូមយាងព្រះអង្គទទួលប្រាប្តាភិសេកឡើងសោយរាជសម្បត្តិនោះ ព្រះអង្គទ្រង់ប្រកែកព្រោះរក **គ្រឿងសំរាប់រាជ្យ** មិនទាន់ឃើញ ។ បើតាមរាជពង្សាវតារខ្មែរថា គ្រឿងទាំងនោះគេអាចរកឃើញឡើងវិញដោយសារតែក្រឡាពាសម្នាក់ដេកយល់សប្តិឃើញគេមកប្រាប់អោយទៅយក ។

រួមសេចក្តីមក យើងឃើញថា **គ្រឿងសំរាប់រាជ្យ** ដូចបានពោលខាងលើនេះមានសារៈសំខាន់ណាស់ ។ បុគ្គលដែលឡើងសោយរាជ្យតែពុំមានគ្រឿងនេះទេ គេចាត់ទុកថា ពុំមានលក្ខណៈជាស្តេចទ្រង់រាជ្យពេញលេញទេ ។ ដោយហេតុនេះ ក្នុងគ្រាអាសន្នបើទោះបីមានគ្រោះថ្នាក់យ៉ាងណាក៏ដោយក៏ពួកព្រាហ្មណ៍បាគូសេវកាមាត្យត្រូវខំរំដោះគ្រឿងសំរាប់រាជ្យនេះអោយបាន តួយ៉ាងដូចកាលពីគ.ស. ១៣៥២នៅពេលដែលសៀមវាយបែករាជធានីអង្គរក្នុងរជ្ជកាលព្រះបាទ **លំពង់រាជា** នោះ ពួករាជ្យគ្រូបុរោហិតបាននាំយក **គ្រឿងសំរាប់រាជ្យ** វាយទំលាយទព័សៀមរត់រួចចេញទៅ ។

ដូច្នេះ យើងឃើញថាអំណាចរបស់ព្រះរាជាស្ថិតនៅលើព្រះរាជពិធី **រាជាភិសេក** នេះ ១ និងលើ **គ្រឿងសំរាប់រាជ្យ**នេះ១ ។ អំណាចទាំងឡាយមានប្រភពចេញមកពីព្រះរាជា ។ ព្រះអង្គជាអ្នកតាក់តែងច្បាប់ ប៉ុន្តែជាច្បាប់សាធារណៈប៉ុណ្ណោះ (22) ។ ព្រះអង្គក៏ជាអគ្គមេបញ្ជាការលើកងទ័ពជាតិ ហើយតែងតែលើកទ័ពផ្ទាល់ព្រះអង្គទៅប្រយុទ្ធប្រឆាំងនឹងមារសត្រូវទាំងខាងក្រៅប្រទេសក៏ដូចជាខាងក្នុងប្រទេស :ដោយហេតុនេះបានជាយើងឃើញ **ព្រះស្រីរាជា** លើកទ័ពផ្ទាល់ព្រះអង្គទៅរំដោះយក

អាណាខេត្តខាងលិច ព្រះ**ចន្ទរាជា** ព្រះ**បរមរាជាទី ៤** និងព្រះ**សត្ថាទី ១** សុទ្ធតែបានលើកទ័ពវាយយកទឹកដីខ្មែរដែលត្រូវបាត់បង់ ហើយសុទ្ធតែបានទៅដល់រាជធានីស្រី **អយុធ្យា** ចំណែកឯព្រះ**បរមរាជាទី៤** ទ្រង់បានលើកទ័ពចេញទៅតទល់នឹងស្តេចលាវដែលមកសងសឹកក្រោយពីប្រជល់ដំរីចាញ់ខ្មែរ ។

ដោយសារព្រះរាជពិធីរាជាភិសេក ព្រះរាជាក៏បានក្លាយទៅជាមេសាសនាផងដែរ ។ ព្រះអង្គមានសិទ្ធិជ្រើសរើសមន្ត្រីសង្ឃ និងមានសិទ្ធិដកសក្តិពីមន្ត្រីប្រភេទនេះទៀត ។ ដោយសារព្រះរាជពិធីដដែលនេះ ព្រះរាជាក៏មានឋានៈជា **ម្ចាស់ជីវិតលើត្បូង** មានសិទ្ធិអោយស្លាប់ អោយរស់លើសព្វសត្វនៅលើផែនដី បានសេចក្តីថា ព្រះអង្គជាចៅក្រមម្នាក់អាចវិនិច្ឆ័យទោសកំហុសជាយថាហេតុ ប៉ុន្តែក្នុងករណីចុងក្រោយនេះ ក៏ដូចជាក្នុងករណីឯទៀតៗដែរ ព្រះអង្គត្រូវប្រកបដោយ **ទសពិធរាជធម៌** មាន **ទាន សីល** នេះជាដើម ។

ដូច្នេះ ទោះបីព្រះរាជាជាប្រភពនៃអំណាចគ្រប់បែបយ៉ាង កាន់កាប់អំណាចគ្រប់ប្រភេទក៏ដោយ ក៏ពុំមានសេចក្តីថា ព្រះអង្គជាអ្នកកាន់អំណាចផ្តាច់ការទេ ។ ផ្ទុយទៅវិញព្រះអង្គត្រូវប្រកប ដោយសីលធម៌អោយបរិបូណ៌ និងគោរពច្បាប់ថែមទៀតផង ។ ការដែលមានព្រះរាជាខ្លះដូចជា **ចៅពញាអន** និង **ចៅពញាញោម** ពុំគោរពក្រិត្យវិន័យសំរាប់ស្តេចទ្រង់រាជ្យហើយបែរជាប្រព្រឹត្ត អំពើអបាយមុខរំលោភលើរូបប្រពន្ធកូនអ្នកដទៃបណ្តាលអោយមានវឹកវរក្នុងផ្ទៃប្រទេសនោះ គឺជាអំពើពុំសមរម្យចំពោះអ្នកដឹកនាំជាតិដែលត្រូវមានករណីយកិច្ចមើលសុខទុក្ខលើអាណាប្រជានុរាស្ត្រទេ ។

ក្នុងសម័យកាលដែលយើងបានលើកមកសិក្សាក្នុងទីនេះ យើងឃើញថាព្រះរាជាដែលសោយរាជ្យបន្តបន្ទាប់គ្នា ទ្រង់បានគង់នៅក្នុងរាជធានីបីសំខាន់ គឺរាជធានី**ភ្នំពេញ ចតុមុខ** រាជធានី **លង្វែក** និង រាជធានី **ទួលបាសានស្រីសន្ធរ** ។ តាមពត៌មានដែលឯកសារផ្សេងៗ បានផ្តល់ និងតាមដែលយើង អាចពិនិត្យឃើញពេលសព្វថ្ងៃនេះ ឃើញថាទីតាំងនៃរាជធានីទាំងនោះសុទ្ធតែជាចំណុចយុទ្ធសាស្ត្រ ស្ថិតនៅជិតទន្លេ បឹង និងព្រៃ ជាឧបសគ្គសំរាប់ការពារខ្លួនបានស្រួល ។ ម្យ៉ាងទៀត រាជធានីនិមួយៗសុទ្ធតែមានកំពែង និងគូ ឬ អូរ ព័ទ្ធជុំវិញ ហើយមានបន្ទាយមានសើននៅច្រើនកន្លែងសំរាប់ការពារទៀត ។ រាជធានីលង្វែកជាបន្ទាយមួយមាំមួនជាងបន្ទាយឯទៀត នេះគឺដោយសារតែមានព្រៃឫស្សីយ៉ាងក្រាសដែលព័ទ្ធពីក្រៅគូទឹកទៀត ប៉ុន្តែនៅតែធ្លាក់ទៅក្នុងកណ្តាប់ដៃសៀម ដោយខ្មែរយើងចាញ់កលល្បិចគេ ។

គួរគប្បីបញ្ជាក់ថា ក្រៅពីអគ្គមហេសីព្រះរាជានៅមានស្រីស្នំស្រីង្គារជាច្រើនទៀត ដែលគេអាចចែកការងារជាច្រើនថ្នាក់ គឺពីទាបទៅខ្ពស់ :

- **អ្នកនាង** (ឧ.អ្នកនាងពៅ មាតារបស់ព្រះជ័យជេដ្ឋាទី ១ និងចៅពញាតន់)
- **អ្នកម្នាង** (ឧ. អ្នកម្នាងទេវី មាតាព្រះនារាយណ៍រាជា)

- **ព្រះម៉ែនាង** (ឧ. ព្រះម៉ែនាងវង មាតាចៅពញាអន)

- **ព្រះម្នាង** (ឧ. ព្រះម្នាងកេសរមាលា មាតាស្រីសុរិយោពណ៌)

ពេលសោយទិវង្គតទៅ គេតែងលើកព្រះសពតំកល់ក្នុងកោដ្ឋ ធ្វើបុណ្យថ្វាយព្រះភ្លើង រួចយកបរមអដ្ឋិធាតុទៅបញ្ចុះក្នុងចេតិយដែលច្រើនតែសាងនៅលើភ្នំ ដូចជាភ្នំដូនពេញ(ចេតិយព្រះបរមរាជាទី ២ ចៅពញយ៉ាត) ភ្នំព្រះរាជទ្រព្យ (ចេតិយព្រះចន្ទរាជា) ។ ល ។ ក្នុងករណីគូបដិបក្សជាប់ញាតិ វង្សហើយត្រូវធ្វើគុត ក៏ព្រះរាជាតែងធ្វើបុណ្យថ្វាយព្រះភ្លើងដល់ព្រះសពអោយសមឋានៈជាក្សត្រដែរ ដូចជា **ព្រះធម្មរាជាទី ១** ទ្រង់បានសុំសពព្រះរៀមគឺព្រះ**ស្រីរាជា** និងក្មួយគឺ **ស្រីសុរិយោទ័យ** ពីព្រះចៅសៀម និងព្រះ**ចន្ទរាជា** បានបញ្ជាអោយគេយកសព **ពញាអុង** ពីសមរភូមិកាលដែលលើក ទ័ពចូលមកវាយខ្មែរ ដើម្បីយកទៅធ្វើពិធីថ្វាយព្រះភ្លើងតាមប្រពៃណីក្សត្រ ។

## ១.២. ពួកបរិវារ

គេឃើញមានជាអាទិរាជវង្សានុវង្សគឺ :

**ឧតយោរាជ** : តាមន័យដើម ពាក្យនេះមានន័យថា ក្សត្រដាក់រាជ្យអោយអង្គណាមួយ សោយតំណាងព្រះអង្គ ទទួលរាជសក្តិជាក្សត្រកណ្តាលជួយដាស់តឿនក្រើនរំលឹកក្សត្រទ្រង់រាជ្យ និង ក្សត្រឧបរាជទាំងពីរអង្គ អោយស្ថិតនៅក្នុងទសពិធរាជធម៌ ប៉ុន្តែក្នុងភាពពិតជាក់ស្តែងវិញ **ឧតយោរាជ** ជាក្សត្រដែលមានព្រះឋានៈបន្ទាប់ពីក្សត្រទ្រង់រាជ្យ (ឧ. **ព្រះស្រីសុរិយោពណ៌**) ។

**ឧបរាជ** ឬ **មហាឧបរាជ** : ឋានៈជា **ឧបរាជ** នេះមានមកជាយូរណាស់មកហើយ ។ គេជ្រើសរើស **ឧបរាជ** ក្នុងចំណោមបុត្រច្បង ឬ អនុជក្សត្រទ្រង់រាជ្យដែលមានគុណវុឌ្ឍិដ៏ខ្ពង់ខ្ពស់ ប៉ុន្តែក្នុងភាពពិតជាក់ស្តែងពុំមែនសុទ្ធតែមានដំណើរប្រព្រឹត្តទៅបែបនេះទេ ព្រោះកាលដែលព្រះ **សត្ថាទី១** ដាក់រាជ្យថ្វាយទៅព្រះរាជបុត្រច្បងនាមព្រះ**ជ័យជេដ្ឋា** ដែលមានព្រះជន្ម ១១ វស្សាអោយឡើងសោយរាជ្យ និងលើកព្រះរាជបុត្របន្ទាប់នាម **ចៅពញាតន់** ដែលមានព្រះជន្មទើបបាន ៦ វស្សា អោយឡើងឋានៈជា **ឧបរាជ** នោះ អំពើនេះធ្វើអោយមានការអាក់អន់ស្រពន់ចិត្តច្រើន ក្នុងចំណោមនាម៉ឺនសព្វមុខមន្ត្រី និងអាណាប្រជានុរាស្ត្រ ។

- ព្រះ **វររាជមាតា** ឬព្រះ **វររាជអយ្យិកា** ក៏ទំនងជាមានឥទ្ធិពលខ្លាំងក្លាណាស់ដែរ ព្រោះ កាលដែលព្រះ**កែវហ្វាទី ១ ចៅពញាញោម** មិនប្រកបដោយទសពិធរាជធម៌ សម្តេចព្រះ **ទេវីក្សត្រី** ត្រូវជាសម្តេចព្រះអយ្យិកាបានជំនុំនឹងមន្ត្រី រួចផ្ញើសារទៅក្រុង **អយុធ្យា** ក្រាបទូលព្រះចៅសៀមបើកសម្តេចព្រះ **ស្រីសុរិយោពណ៌** អោយចេញមកក្រុងកម្ពុជាធិបតីវិញ ។

**ចៅហ្វាឧត្តម** ៖ បើប្រៀបធៀបនឹងសព្វថ្ងៃ **ចៅហ្វាឧត្តម** មានបណ្តាសិក្តស្មើនឹង **នាយករដ្ឋមន្ត្រី** ឬ **រដ្ឋមន្ត្រីទី១** ។ បន្ទាប់ពី **ចៅហ្វាឧត្តម** មកគេឃើញមានមន្ត្រីជាន់ខ្ពស់ ៤រូបទៀត ដែលមានមុខងារជាអ្នកសំរេចរាជការ និងគ្រប់គ្រងផែនដីរួម និងព្រះមហាក្សត្រ ។ មន្ត្រីជាន់ខ្ពស់ទាំង៤នេះគេចាត់ដូចសសរជើងរៀងទាំង ៤នៃប្រាសាទ ទើបមាននាមរួមថា **ចតុស្តម្ភ** ៖

- ឧកញ៉ាក្រឡាហោម
- ឧកញ៉ាវាំង
- ឧកញ៉ាយមរាជ
- ឧកញ៉ាចក្រី ។

**មហាតលិក** ៖ នេះជាមន្ត្រីខ្ញុំរាជការដែលមានមុខងារគាល់បំរើព្រះរាជា ។ **ស្តេចកន** កាលពីដើមជា **មហាតលិក** មួយរូបដែលត្រូវបានព្រះបាទ **ស្រីសុគន្ធបទ** តម្កើងអោយឡើងឋានៈជា **ឃុនឃ្លាំងព្រះស្តេច** ។

**ហោរា** ៖ ជាមន្ត្រី១ប្រភេទដែលមានមុខងារសំខាន់ណាស់ដែរ ព្រោះក្នុងសម័យនោះ តាំងពីក្សត្រទ្រង់រាជ្យដល់អាណាប្រជានុរាស្ត្រសុទ្ធតែមានជំនឿលើការទស្សន៍ទាយ ។ មុននឹងលើករាជធានីពីទួលបាសានមកភ្នំពេញ ព្រះ**បរមរាជាទី២ ចៅពញាយ៉ាត** ទ្រង់បានបញ្ជា **ឧកញ៉ាហោរាធិបតីខៀវ** និងមន្ត្រីឯទៀតអោយមកពិនិត្យមើលកន្លែងតាមក្បួនហោរាសិន ។ ឯព្រះបាទ**ស្រីសុគន្ធបទ** ពេលទ្រង់យល់សុបិនឃើញនាគដេញពាំស្វេតច្ឆត្រ ក៏បានអោយហោរាទស្សន៍ទាយទៅឃើញថាមានគេចង់ជ្រែករាជ្យ គឺស្តេចកននេះឯង ។

**ចៅជិត ចៅចម** ៖ **ចៅជិត** គឺពួកស្ត្រីជាព្រះរាជបរិវារ មានមុខងារក្រាបបង្គំគាល់បំរើជិតស្និទ្ធក្នុងព្រះរាជត្រកូល ឯ**ចៅចម** គឺពួកស្ត្រីជារាស្ត្រសាមញ្ញដែលគេថ្វាយអោយធ្វើជាមហេសីស្តេច បានដល់ពួក**ស្រីស្នំស្រីក្ពារ**នេះឯង ។

## ១.៣. ការបន្តរាជសម្បត្តិ

ជាទូទៅ គេសង្កេតឃើញរាជសម្បត្តិត្រូវបានបន្តពីបិតាជាក្សត្រទ្រង់រាជ្យទៅបុត្រ បានសេចក្តីថា នៅពេលដែលព្រះបិតាសោយទិវង្គតទៅ ឬក៏ដាក់រាជ្យ គឺបុត្រច្បងត្រូវមានសិទ្ធិឡើងសោយរាជ្យស្នងហើយប្រសិនបើបុត្រច្បងត្រូវសុគតមុនសោយរាជ្យ គឺបុត្របន្ទាប់មានសិទ្ធិសោយរាជ្យស្នងព្រះបិតា ។ ដោយហេតុនេះហើយទើបយើងឃើញ ព្រះ**នារាយណ៍រាជា**ឡើងសោយរាជ្យស្នងព្រះ **បរមរាជាទី២ ចៅពញាយ៉ាត** ព្រះ **សត្ថាទី១** សោយរាជ្យស្នងព្រះ**បរមរាជាទី៤** ឯ**ព្រះបរមរាជាទី៤** បានសោយរាជ្យ

ស្នងពីព្រះ**ចន្ទរាជា** ព្រោះបុត្រច្បងនាម **រាមា ធិបតី** បានសុគតមុនសោយរាជ្យ (តាមរាជពង្សាវតារខ្លះថាត្រូវព្រះធរណីស្រូប) ។

ក្នុងករណីដែលក្សត្រទ្រង់រាជ្យពុំមានបុត្រសោយរាជ្យស្នងទេ សិទ្ធិនេះត្រូវបានទៅព្រះអនុជជាបន្តបន្ទាប់គ្នា ។ ព្រះ**ចន្ទរាជា** បានឡើងសោយរាជ្យជាតំណវង្សពីព្រះបាទ**ស្រីសុគន្ធបទ** ព្រោះរាជបុត្រក្សត្រអង្គនេះ គឺ**ពញាយសរាជា** បានសុគតមុនសោយរាជ្យ ។ ប្រសិនបើគេមិនគោរពទំលាប់នេះទេនោះវិបត្តិច្បាស់ជាកើតឡើងចៀសមិនបាន : នេះគឺជាករណីរបស់ **ស្រីសុរិយោទ័យ** ដែលត្រូវបានឡើងសោយរាជ្យស្នងព្រះបិតា គឺព្រះ**នារាយណ៍រាជា** តែពុំដូច្នោះបែរជាបានទៅព្រះ **ស្រីរាជា** ជាអនុជសោយរាជ្យវិញ ជាហេតុនាំអោយមានចម្បាំងគ្នាឯងក្នុងស្រុកអស់រយៈពេល ១០ឆ្នាំ (១៤៧៥-១៤៨៥) ។

ក្នុងសម័យកាលដែលយើងលើកយកមកសិក្សានេះ គេសង្កេតឃើញថាមានអន្តរាគមន៍របស់ពួកមន្ត្រីក្នុងការជ្រើសរើសក្សត្រអោយឡើងសោយរាជ្យ ហើយអន្តរាគមន៍នេះមាន ប្រសិទ្ធិភាពខ្លាំងណាស់ដែរ ។ យ៉ាងណាមិញព្រះ **ស្រីរាជា** ព្រះ **បរមរាជាទី៧ ចៅពញាអន** និងព្រះ **ស្រីសុរិយោពណ៌** សុទ្ធតែបានឡើងសោយរាជ្យដោយសារតែអន្តរាគមន៍របស់នាម៉ឺនសព្វមុខមន្ត្រីនេះឯង ។

ក្នុងករណីដែលបុគ្គលណាមួយ ទោះជាមន្ត្រីជាន់ខ្ពស់ក្តី ទោះជាជាប់ព្រះញាតិនឹងក្សត្រទ្រង់រាជ្យក្តី តែបើពុំមានសិទ្ធិទទួលរាជសម្បត្តិទេ ហើយបែរជាប្រើកម្លាំងអាវុធដើម្បីបានឡើងសោយរាជ្យនោះគេអោយឈ្មោះហៅថាស្តេចជ្រែករាជ្យ (**ស្តេចកន ព្រះរាមជើងព្រៃ**) ។

## ២. នយោបាយក្នុងប្រទេស

គេសង្កេតឃើញមានវិបត្តិក្នុងរាជ្យវង្សជាញឹកញាប់ ជាហេតុបណ្តាលអោយមានចម្បាំងគ្នាឯងក្នុងស្រុក : ចម្បាំងរវាង**ស្រីរាជា ស្រីសុរិយោទ័យ ធម្មរាជា** អស់រយៈពេល ១០ឆ្នាំ (១៤៧៥- ១៤៨៥) និងចម្បាំងរវាង **ស្រីសុគន្ធបទ ស្តេចកន ចន្ទរាជា** (១៥០៩-១៥១២ និង ១៥១៦- ១៥២៥) ។ មូលហេតុនៃចម្បាំងទាំងនេះ គឺបណ្តាលពីការគិតប្រយោជន៍ផ្ទាល់ខ្លួនច្រើនជាងប្រយោជន៍រួម ។ យ៉ាងណាមិញ ព្រះ**ស្រីសុរិយោទ័យ** ច្បាំងនឹង**ព្រះស្រីរាជា** មកតែពីគិតប្រយោជន៍ផ្ទាល់ គឺសិទ្ធិត្រូវបានសោយរាជ្យស្នងព្រះបិតា ព្រះ **បាទស្រីសុគន្ធបទ** រកកលសម្លាប់ **ស្តេចកន** មកតែពីខ្លាចមន្ត្រីរូបនេះដណ្តើមរាជសម្បត្តិ **ព្រះសត្ថាទី ១** បានដាក់រាជ្យថ្វាយទៅបុត្រដែលសុទ្ធតែមានវ័យក្មេងៗ ព្រោះតែខ្លាចរាជសម្បត្តិបានទៅព្រះអនុជគឺ **ស្រីសុរិយោពណ៌** ដែលមានសមត្ថភាព និងមានប្រជាប្រិយភាពជាង ។

លុះជម្លោះកើតឡើងហើយ អ្នកដឹកនាំជាតិមិននិយមការដោះស្រាយដោយសម្របសម្រួលគ្នាទេ បែរជាសុខចិត្តទៅពឹងពាក់អោយបរទេសជិតខាងចូលមកផ្សះផ្សាវិវាទផ្ទៃក្នុងរបស់ខ្មែរទៅវិញ ។ ដោយហេតុនេះហើយ ទើបព្រះ **ធម្មរាជា** ទ្រង់បានទៅអន្ទងស្តេចសៀមអោយលើកទ័ពចូលមក ធ្វើកលចាប់ព្រះ**ស្រីរាជា** និង**ស្រីសុរិយោទ័យ** យកទៅស្រុកសៀមអស់ទៅ ។

## ៣. នយោបាយក្រៅប្រទេស

នៅគ្រានោះខ្មែរមិនទាន់មានកង្វល់នៅព្រំដែនខាងកើតនៅឡើយទេ ព្រោះប្រទេស **ចាម្ប៉ា** កំពុងតែជាប់ដៃធ្វើចម្បាំងជាមួយយួនពួក **ឡេ** ដែលបានលេបទឹកដីរបស់រាជាណាចក្រនេះបន្តិចម្តងៗ ។

ប៉ុន្តែព្រំដែនខាងលិច ព្រះរាជាខ្មែរបានព្យាយាមវាយរំដោះយកទឹកដីដែលត្រូវបាត់បង់ទៅតាំងពី ស.វ.ទី ១៣ រៀងមក ។ គឺក្នុងគោលបំណងនេះហើយដែលព្រះ **ស្រីរាជា** ព្រះ **ចន្ទរាជា** ព្រះ **បរមរាជាទី៤** ព្រះ **សត្ថាទី ១** បានលើកទ័ពទៅវាយលុករហូតដល់រាជធានី **ស្រីអយុធ្យា** ហើយរំដោះ យកបានទឹកដីមកវិញជាច្រើនមែន ។ ឯហេតុដែលនាំអោយខ្មែរមានជោគជ័យបែបនេះ គឺបណ្តាលមកពីភូមាបានលើកទ័ពចូលវាយសៀមជាញឹកញយ វាយយកបានរាជធានី **ស្រីអយុធ្យា** ២លើក (គ.ស. ១៥៦៤ និង ១៥៦៩) និងដាក់ប្រទេសសៀមជាចំណុះអស់ ១៥ឆ្នាំទៀតផង ហើយស្តេចខ្មែរចេះឆ្លៀតយកឱកាសដែលសត្រូវកំពុងតែទន់ខ្សោយនោះលើកទ័ពចូលវាយបន្ថែមទៀត ហើយអាចរំដោះយកបានទឹកដីដែលត្រូវបាត់បង់មកវិញ ។ ត្រង់ចំណុចនេះ ឯកសារអឺរ៉ុប(19) និយាយថាខ្មែរបានធ្វើសម្ព័ន្ធមិត្តជាមួយភូមាដើម្បីវាយសៀម ប៉ុន្តែឯកសារខ្មែរមិនបាននិយាយដល់រឿងនេះទេ ។ ប្រភពអឺរ៉ុបដដែលបានបន្ថែមទៀតថាក្រោយមកខ្មែរបានងាកទៅចងសម្ព័ន្ធមេត្រីជាមួយសត្រូវខ្លួន(សន្ធិសញ្ញាខ្មែរ-សៀម គ.ស. ១៥៧៤ ព្រះ **សត្ថាទី ១** បញ្ជាអោយ **ស្រីសុរិយោពណ៌** លើកទ័ពទៅជួយសៀមវាយឈ្នះភូមា) ប៉ុន្តែមិនបានផលល្អ ព្រោះក្រោយពីបានរំដោះខ្លួនពីចំណុះភូមាមក សៀមតែងបានលើកទ័ពចូលវាយខ្មែរញឹកញាប់ ថាព្រោះតែខ្មែរមិនរក្សាពាក្យសច្ចៈ ។ ការពិត សៀមធ្វើនេះ គឺនៅក្នុងក្របខ័ណ្ឌពង្រីកទឹកដីរបស់គេតែប៉ុណ្ណោះ ។ ម្ល៉ោះហើយនៅចំពោះមុខគ្រោះថ្នាក់ដែលតែងតែគំរាមកំហែងមកលើប្រទេសជាតិនេះ ព្រះរាជាខ្មែរចាប់ពីព្រះ **សត្ថាទី ១** រៀងមកបានងាកទៅរកជំនួយពីពួកព័រទុយក័លហើយក្រោយមកពីពួកអេស្ប៉ាញទៀត ។ ព្រះអង្គទ្រង់បានយកចិត្តអ្នកផ្សាយសាសនាអឺរ៉ុបយ៉ាងខ្លាំងដើម្បីអោយពួកនេះជួយធ្វើអន្តរាគមន៍សុំជំនួយទ័ពមកប្រឆាំងនឹងសៀម ។ ព្រះអង្គទ្រង់បានសន្យាថានឹងបើកសិទ្ធិអោយពួកនេះ ផ្សាយសាសនាគ្រិស្តនៅគ្រប់ទិសទីក្នុងព្រះរាជាណាចក្ររបស់ព្រះអង្គជួយសង់ព្រះវិហារ និងផ្តល់ទេយ្យទាន មានអង្ករជាដើមដល់ពួកនេះ ។ ពួកអេស្ប៉ាញនៅម៉ានីល មានបំណងចង់មកតាំងអាណាព្យាបាលភាពលើប្រទេសខ្មែរហើយបានបញ្ជូនទ័ព និងអ្នកផ្សាយសាសនាមកប្រទេសខ្មែរជាច្រើនលើក តែពុំបានសំរេចដូចប្រាថ្នា ។ នៅទីបំផុត ព្រះ **ស្រីសុរិយោពណ៌** ដែលទ័ពសៀមចាប់នាំយកទៅក្រុង **អយុធ្យា** បានត្រឡប់ចូលមកប្រទេសខ្មែរវិញដោយនាំយកឥទ្ធិពលរបស់សៀមមកផ្សាយទៀត ។ គួរគប្បីបញ្ជាក់ថា ពួកសៀមដែលកាន់ព្រះពុទ្ធសាសនាដូចខ្មែរដែរនោះ បានប្រឆាំងយ៉ាងខ្លាំងចំពោះការប៉ុនប៉ងផ្សាយសាសនារបស់ជនជាតិអឺរ៉ុប ជាពិសេសក្នុងរជ្ជកាលរបស់ព្រះ **នរេសូរ** ។

## ខ. រដ្ឋបាល

### ១. ការបែងចែកអាណាចក្រ

នៅសម័យនោះ ប្រទេសខ្មែរលែងជាមហាអំណាចមួយខាងទឹកដីទៀតហើយ :ទឹកដីជាន់ក្រៅ គឺ ស្រុក **បច្ចន្តជនបទ** ដូចជាស្រុក **សុខោទ័យ** ស្រុក **ស្រីអយុធ្យា** ស្រុក **លពបុរី** ស្រុក **គោរាត្របុរ (តិម៉ាយ)** ត្រូវបាត់បង់អស់ទៅហើយ ឯប្រទេសសាមន្តរាជ ដូច **ចាម្ប៉ា** **អាណ្ណាម** **ថ្វា** **មន** ក៏លែងមានទៀតដែរហើយ ។ ព្រំដែនខាងជើងរបស់ខ្មែរធ្លាក់មកនៅត្រឹម **ឱន្លេមូល** ឬនៅលើនេះ បន្តិចបន្តួច និងប្រទេសលាវ ។ ព្រំដែនខាងលិចទល់នឹង **បស្ចិមបុរី** និង **រយ៉ង** ខាងពាយ័ព្យទល់នឹងស្រុក **នាខរខនគររាជ** ខាងកើតទល់នឹងប្រទេស **ចាម្ប៉ា** ខាងត្បូងទល់នឹងសមុទ្រចិន និងឈូងសមុទ្រសៀម ។

បើតាមរាជពង្សាវតារ រាជាណាចក្រខ្មែរសម័យនោះមានប្រមាណជា ៧០ខេត្ត គឺ: **លង្វែក** **អម្រិន្ទបុរ** **ក្រគរ** **ក្រង** **ពោធិ៍សាត់** **បាត់ដំបង** **ឫស្សីសាញ** **តាមសីមា** **មង្គលបុរី** **រយ៉ង** **សុរិន្ទ** **សង្កែរ** **កំពង់សៀម** **ស្ទឹងត្រែង** **ជើងព្រៃ** **គោកសេះ** **អន្លង់រាជ** **ព្រាំទេព** **ព្រៃក្ដី** **ស្ពានខ** **ជីក្រែង** **រលួស** **សៀមរាប** **កំពង់ស្វាយ** **ម្លូព្រៃ** **ជាំក្សាន្ត** **ត្នោត** **ទឹកជោរ** **សៀមបូក** **សម្បុកសម្បូណ៌** **ក្រចេះ** **ឆ្លូង** **ត្បូង** **បាសាន** **ធនិងថ្ងៃ** **ព្រៃវែង** **ត្បូងឃ្មុំ** **បាភ្នំ** **រំដួល** **ស្វាយទាប** **រោងដំរី** **ព្រៃនគរ** **លង់ហោរ** **ជើងបាដែង** **សំរោងទង** **បាទី** **លើកដែក** **ទ្រាំង** **បន្ទាយមាស** **ថ្កូង** **បាសាក់** **បារៀ (បារា)** **ពាម** **កោះស្លាកែត** **កំពត** **កំពង់សោម** **ទឹកខ្មៅ** **ពាមមេសរ** **ព្រះត្រពាំង** **ក្រមួនស** **ដូនណៃ** ។ល។

គួរកត់សំគាល់ថាក្នុងចំណោមខេត្តទាំងប៉ុន្មាននេះ ខេត្តខ្លះនៅឋានៈជាខេត្តរហូតមកដល់សព្វថ្ងៃនេះដូចជា **ពោធិ៍សាត់** **បាត់ដំបង** **ស្ទឹងត្រែង** **សៀមរាប** **ក្រចេះ** **ព្រៃវែង** ។ល។ ឯខេត្តខ្លះទៀតធ្លាក់ឋានៈមកជាស្រុកវិញ ដូចជា **មង្គលបុរី** **ស្ពានខ** **ជីក្រែង** **រលួស** **ទឹកជោរ** ។ល។ ឯខេត្តខ្លះទៀតត្រូវបាត់ឈ្មោះរលាយចូលនឹងខេត្តឯទៀតៗអស់ទៅ ។

**ខេត្ត** និមួយៗ ត្រូវបែងចែកជា**ស្រុក** ហើយស្រុកនិមួយៗត្រូវបែងចែកជា **ភូមិ** ជាច្រើនទៅទៀត ។ ប៉ុន្តែ ខេត្តជាច្រើនត្រូវបានប្រមូលផ្ដុំជាតំបន់ធំៗ ដែលគេអោយឈ្មោះហៅថា **ដី** (22) ។

### ២. រដ្ឋបាលកណ្ដាល

ដោយហេតុព្រះរាជាជាប្រភពនៃអំណាចទាំងឡាយ ហើយពួកបរិវាររបស់ព្រះអង្គសុទ្ធតែជារាជវង្សានុវង្ស និងមន្ត្រីជាន់ខ្ពស់ផងនោះ គេអាចយល់បានថាគឺពួកបរិវារនេះហើយជាអ្នកញ៉ាំងម៉ាស៊ីន

រដ្ឋបាលកណ្ដាលអោយប្រព្រឹត្តទៅ ។ ដូចយើងបានរៀបរាប់រួចមកហើយក្នុងវគ្គនិមួយៗ ពីព្រះរាជបរិវារ ឃើញថាបន្ទាប់ពីស្ដេចទ្រង់រាជ្យមកមាន**ឧតយោរាជ ឧបរាជ** ឬ **មហាឧបរាជ ព្រះវររាជមាតា វររាជអយ្យកា ចៅហ៊្វានឡ្ហះ** និងមន្ត្រីជាន់ខ្ពស់ ៤រូបដែលគេនិយមហៅថា **ចតុស្តម្ភ** គឺ :

- **ឧកញ៉ាយមរាជ** (រដ្ឋមន្ត្រីក្រសួងយុត្តិធម៌)
- **ឧកញ៉ាក្រឡាហោម** (រដ្ឋមន្ត្រីក្រសួងទ័ពជើងទឹក)
- **ឧកញ៉ាវាំង** (រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង)
- **ឧកញ៉ាចក្រី** (រដ្ឋមន្ត្រីខាងទ័ពជើងគោក) ។

ដូច្នេះ **ចៅហ៊្វានឡ្ហះ** និងមន្ត្រីជាន់ខ្ពស់ទាំង ៤រូបនេះប្រៀបបាននឹង **គណៈរដ្ឋមន្ត្រី** សព្វថ្ងៃ ហើយដែលពីដើមគេនិយមហៅថា **សេនាបតី** ។ មន្ត្រីជាន់ខ្ពស់ទាំង៥រូបនេះគេហៅថា **មន្ត្រីសំរាប់ឯក** គឺជាមន្ត្រីដែលត្រូវឡើងទៅ **ព្រះមហាក្សត្រ** : មន្ត្រីទាំងនេះមានមុខងារញ៉ាំងរដ្ឋបាល កណ្ដាលអោយប្រព្រឹត្តទៅផង ហើយមានអំណាចត្រួតត្រាលើខេត្តខ្លះទៀតផង ។ ក្រៅពីនេះនៅមាន **មន្ត្រីសំរាប់ទោ** ត្រូវឡើងទៅជា **ឧតយោរាជ មន្ត្រីសំរាប់ត្រី** ត្រូវឡើងទៅ**ព្រះឧបរាជ** ឬ **មហាឧបរាជ** និង **មន្ត្រីសំរាប់ចត្វា** ត្រូវឡើងទៅព្រះ **វររាជមាតា** ឬ ព្រះ **វររាជអយ្យកា** ។ មន្ត្រីទាំង៤សំរាប់នេះ លើកលែងតែ **ចៅហ៊្វានឡ្ហះ** ចេញដែលមានឋានន្តរសក្តិថា **សម្តេចចៅពញា** សុទ្ធតែមានឋានន្តរសក្តិជា **ឧកញ៉ា** សក្តិ ១០ **ហ៊្វូពាន់** (**ហ៊្វូពាន់** : ពាក្យសៀមមានន័យថាក្បាលពាន់ គឺទ័ព ១០០០នាក់ ដែលនៅក្រោមបង្គាប់របស់មន្ត្រីណាម្នាក់) ។

ក្រៅពីមន្ត្រីជាន់ខ្ពស់ទាំងប៉ុន្មានដូចរៀបរាប់រួចមកហើយនេះ គេឃើញមានមន្ត្រីជាន់កណ្ដាល និងជាន់ទាបជាច្រើនទៀតដែលមានឋានន្តរសក្តិដូចតទៅ :

- **ព្រះ** . . . . . . . . . សក្តិ ៦ ហ៊្វូពាន់
- **ហ្លួង** . . . . . . . . . សក្តិ ៥ ហ៊្វូពាន់
- **ឃុនម៉ឺន** . . . . . . . សក្តិ ៤ ហ៊្វូពាន់
- **ឧក ម៉ឺន** . . . . . . . សក្តិ៣ ហ៊្វូពាន់
- **ចៈ ម៉ឺន** . . . . . . . សក្តិ២ ហ៊្វូពាន់
- **ម៉ឺន** . . . . . . . . . សក្តិ ១ ហ៊្វូពាន់ ។

ចំណែកខ្ញុំរាជការដែលមិនទាន់បានទទួលយសសក្តិនៅឡើយទេ នោះអោយហៅថា **នាយ** ។

## ៣. រដ្ឋបាលភូមិភាគ

ក្នុងផ្នែកទី ១ ដែលទាក់ទងនឹងការបែងចែកអាណាចក្រ យើងបានឃើញថាទឹកដីខ្មែរ ត្រូវចែកជាប្រមាណ ៧០ខេត្ត ហើយ **ខេត្ត** ទាំងនោះត្រូវប្រមូលផ្តុំជាតំបន់ដែលគេហៅថា **ដី** ។ ក្នុងតំបន់និមួយៗ មាន**ស្តេចត្រាញ់**មួយអង្គឈរត្រួតត្រា (ជួនកាលហៅថា **ស្តេចត្រាញ់**ក៏បាន ពាក្យនេះទំនងជាក្លាយមកពីពាក្យបុរាណ **ម្រតាញ** ដែលមានប្រើក្នុងសិលាចារឹកខ្មែរ) ។ **ស្តេចត្រាញ់** មួយអង្គៗមាននាទីគ្រប់គ្រងតំបន់របស់ខ្លួនផង ហើយមាននាទីគ្រប់គ្រងខេត្តរបស់ខ្លួនផ្ទាល់ផង ។ បើតាមឯកសាររាជពង្សាវតារខ្មែរ ក្នុងរជ្ជកាលព្រះបាទ **ធម្មរាជាទី ១** មានការតែងតាំងស្តេចត្រាញ់ ៥ អង្គគឺ :

- **ពញាតេជោ** ចៅហ្វាយស្រុកខេត្តកំពង់ស្វាយ ១
- **ពញាសួគ៌ាលោក** ចៅហ្វាយខេត្តពោធិ៍សាត់ ១
- **ពញាស្រីធម្មាតេជោ** ចៅហ្វាយស្រុកខេត្តបាភ្នំ ១
- **ពញាពិស្ណុលោក** ចៅហ្វាយខេត្តទ្រាំង ១
- **ពញាអរជូន** ចៅហ្វាយស្រុកខេត្តត្បូងឃ្មុំ ១ ។

ដូចបានពោលរួចមកខាងលើនេះ យើងឃើញថាក្នុងខេត្តនិមួយៗ មានមន្ត្រីជាន់ខ្ពស់ម្នាក់ឈរត្រួតត្រា។ មន្ត្រីនេះគេនិយមហៅថា **ចៅហ្វាយស្រុក** : ឧ. មន្ត្រីឈរត្រួត **ខេត្តទ្រាំង** គេហៅថា **ចៅហ្វាយស្រុកខេត្តទ្រាំង** ។

តាមប្រភពរាជពង្សាវតារខ្មែរដដែល គេដឹងថា **ចៅហ្វាយស្រុក** សុទ្ធតែមានសក្តិ ១០ ឬ ៩ ហ៊ូពាន់ពីបុរាណរៀងមក តាំងឡើងសុទ្ធតែជា**សម្តេចចៅពញា** ព្រោះ**ចៅហ្វាយស្រុក** ទាំងនោះសុទ្ធតែជាព្រះញាតិនៃព្រះរាជា តែក្រោយមក **ចៅហ្វាយស្រុក** ទាំងនោះច្រើនតែពុំសូវគោរពកោតខ្លាចសេនាបតីទើបត្រូវទម្លាក់មកនៅត្រឹមតែទី **ចៅពញា** ។ គួរគប្បីជ្រាបដែរថា **ទីចៅពញា** នេះក៏ជាឋានន្តរសក្តិរបស់បុត្រស្តេចទ្រង់រាជ្យដែរ (ឧ. **ចៅពញាដាំខាត់រាជា ចៅពញាចន្ទរាជា ចៅពញាតន់ ចៅពញាអន ចៅពញាញោម** ។ ល ។) ។ បើ **ចៅហ្វាយស្រុក** ណាមានសក្តិ ៨ ឬ ៧ ហ៊ូពាន់ ត្រូវតាំងជា **ពញា** ។

**ខេត្ត**និមួយៗ ត្រូវបែងចែកជាច្រើន **ស្រុក** ដែលគ្រប់គ្រងដោយ **មេស្រុក** ។ ហើយមេស្រុកនិមួយៗទំនងជាត្រូវចែកជា **ឃុំ** ជា **ភូមិ** ដែលមាន **មេឃុំ** និង **មេភូមិ** ជាអ្នកគ្រប់គ្រង ។

## គ. អំពីកងទ័ព

### ១. ការរៀបចំកងទ័ព

ក្នុងសម័យនោះ កងទ័ពខ្មែរត្រូវបែងចែកជា **កងទ័ពជើងគោក** និង**កងទ័ពជើងទឹក** ។

### ១.១. កងទ័ពជើងគោក

**កងទ័ពជើងគោក** ស្ថិតនៅក្រោមអំណាចដឹកនាំរបស់ **ឧកញ៉ាចក្រី** ហើយត្រូវបែងចែកជា ៤ ពួក :

- ពួក **ទ័ព ដំរី** ១
- ពួក **ទ័ព សេះ** ១
- ពួក **ទ័ព រថ** ១
- ពួក **ទ័ព ថ្មើរជើង** ១

ទ័ពទាំង ៤ពួកនេះរួមគ្នាទៅលោកអោយឈ្មោះហៅថា **ចតុរង្គ** ហើយត្រូវបានរាជការចិញ្ចឹមទុកអោយមាននៅប្រចាំការជានិច្ច (21) ។

**ទ័ពដំរី** : **ដំរី** ជាសត្វពាហនៈដ៏សំខាន់ ១ ។ ក្នុងសម័យបុរាណគេអាចប្រៀបសត្វ **ដំរី** ទៅនឹងរថក្រោះសព្វថ្ងៃបាន ក្នុងពេលធ្វើចម្បាំងគេប្រើសត្វ **ដំរី** ក្នុងការដឹកនាំនិងក្នុងការលុកចូលវាយទ័ពខាងសត្រូវ ។ ដោយហេតុនេះហើយ រាជការខ្មែរតាំងពីបុរាណរៀងមក ដរាបដល់បច្ចុប្បន្ននេះបានតាំងភ្នាក់ងារ ១ក្រុមហៅថា **ក្រុមដំរី** មានមុខងារជាអ្នកថែរក្សា **ដំរី** ព្រះរាជទ្រព្យទាំងអស់ និងទាក់ដំរីព្រៃយកមកផ្សាំងបង្ហាត់អោយបានបទតាមដែលត្រូវការ ទុកសំរាប់ប្រើក្នុងរាជការ (21) ។

**ទ័ពសេះ** និង **ទ័ពរថ** : ទ័ពទាំងពីរប្រភេទនេះឡើងសេនាបតីជើងគោកជាមួយគ្នា ។ **សេះ** ជាសត្វពាហនៈ ១ ដែលគេនិយមប្រើណាស់ ក្នុងការធ្វើសង្គ្រាមព្រោះវាមានល្បឿនចាត់ការបានឆាប់ទាន់ពេលវេលា ។ **ទ័ពរថ** ប្រើរថទឹមសេះក៏មាន ប្រើរទេះទឹមគោក៏មាន ។

**ទ័ពថ្មើរជើង** : គឺសំដៅយកពួកសេនាទាហានដែលមិនត្រូវជិះដំរី សេះ ឬរថ ។

ទ័ពទាំង ៤ពួកខាងលើនេះសុទ្ធតែបានទទួលការបង្វឹកបង្ហាត់ក្នុងក្បួនយុទ្ធវិធីតាមសម័យនិយមយ៉ាងជំនាញៗ ។ ឯកសារខ្មែរមួយ(21) បានសរសេរថា : "ការហាត់យុទ្ធវិធីក្នុងជាន់នោះ ក៏គឺការហាត់គុនដាវ គុនល្បុក្កតោ គុនដំបង ហាត់កាប់ដោយដាវ ដោយផ្គាក់ ហាត់ចាក់ដោយលំពែង ហាត់បាញ់ដោយធ្នូ ហាត់ដាល់ ហាត់ចំបាប់ ហាត់ជិះដំរី ជិះសេះ ជិះរថ ហាត់ក្បាច់អាវុធលើខ្នងដំរី ខ្នងសេះ

និងរៀនប្រសិទ្ធិមន្តអាគមតាមលទ្ធិសៃយ ដូចយ៉ាងបញ្ចុះមន្តអាគម- យ័ន្តនៅអាវ នៅកន្សែងសំរាប់ជួតក្បាល សាក់តាមខ្លួន និង ផឹកថ្នាំគង់ជាដើម និងសិក្សាក្នុងក្បួនកលយុទ្ធ មានតម្រាពិជ័យ សង្គ្រាមជាដើមសឹងប្រកបដោយយុទ្ធវិធីផ្សេងៗជាច្រើន បម្រុងទុកសំរាប់ប្រើការក្នុងយាមមានសឹក សង្គ្រាម " ។

ក្រៅពីទាហានដែលប្រចាំការទាំង ៤ ពួកខាងលើនេះ នៅមាន **ទាហានក្រៅតំណែង** ជាច្រើនទៀត ។ ប្រភពដដែលខាងលើ (21) បានអោយពត៌មានថា : "**ទាហានក្រៅតំណែង** នេះសំដៅយកយុវជនដែលនៅក្នុងព្រះរាជាណាចក្រទាំងមូល ពួកនេះមិនបានកែនមកអោយនៅប្រចាំការទេ ដោយអនុញ្ញាតអោយនៅធ្វើការរកស៊ីតាមទីលំនៅរៀងខ្លួន តែបានដាក់អោយជាភារៈរបស់អ្នករាជការដែលគ្រប់គ្រងនិគម ស្រុកខេត្តនោះ ចាត់ការបណ្តុះបណ្តាលវិជ្ជាខាងទាហាន និងអោយមាននិស្ស័យចិត្តជាទាហានទូទៅក្នុងប្រទេសតាមរបៀបដូចមានពោលហើយខាងដើម... ទាហានពួកនេះពិតមែនតែមិនបានកែនមកនៅប្រចាំការ តែមានព្រះរាជកំណត់ត្រាទុកថា ត្រូវកែនមកធ្វើការ **សមយុទ្ធ** ក្នុងក្រុងថ្វាយព្រះករុណាម្ចាស់ផែនដីទតនិងធ្វើ**ពិធីបន្តក់ប្រសិទ្ធិ ពិធីផឹកទឹកពិតន្តសច្ចា** រាល់ៗឆ្នាំក្នុង១ឆ្នាំ២ដង" ។

## ១.២. កងទ័ពជើងទឹក

ទ័ពប្រភេទនេះត្រូវស្ថិតនៅក្រោមការដឹកនាំរបស់ **ឧកញ៉ាក្រឡាហោម** ។ រៀងរាល់ឆ្នាំ ទ័ពនេះត្រូវប្រជុំធ្វើសមយុទ្ធ ដូចទ័ពជើងគោកដែរ ឃើញមានស្នាមធ្វើរៀងមកដល់សម័យបច្ចុប្បន្ន តែក្លាយទៅជាការប្រណាំងទូកសំរាប់មើលលេង ក្នុងឱកាសបុណ្យបណ្តែតប្រទីបបូជាព្រះពុទ្ធបាទ និងបុណ្យបូជាព្រះចន្ទទៅវិញ (21) ។

## ១.៣. ចំណែកទ័ព

តាមឯកសារខ្លះ (21) និងតាមការស្រាវជ្រាវរបស់អ្នកប្រវត្តិសាស្ត្រខ្មែរ ជាពិសេសការស្រាវជ្រាវខាងប្រវត្តិសាស្ត្រខ្មែរ (23) យើងអាចដឹងពីការបែងចែកទ័ពខ្មែរ ទោះជាខាងជើងគោកក្តី ខាងជើងទឹកក្តីដូចតទៅ :។

**ពួក** : នេះជាឯកភាពតូចបំផុតនៃកងទ័ព មាន**មេពួកម្នាក់** ជាអ្នកគ្រប់គ្រង

**ក្រុម** : មាន **មេ** ឬ **នាយក្រុម** ម្នាក់ជាអ្នកគ្រប់គ្រង ។

**កងរយ** : មានទាហានចំនួន ១០០នាក់ ប្រៀបបាននឹងអនុសេនាធំ ១ក្នុងពេលសព្វថ្ងៃមាន **មេបន្ទាប់** ម្នាក់ជាអ្នកគ្រប់គ្រង ។

**កងពាន់** : មានទាហានចំនួន ១០០០នាក់ មាន**មេបន្ទាប់ការ** ម្នាក់ជាអ្នកគ្រង់គ្រង ។

**កងទ័ពតូច** ឬ **កងពល** ៖ មានទាហានចំនួន ១០ ០០០នាក់មាន **មេបញ្ជាការកងពល** ម្នាក់ជាអ្នកគ្រប់គ្រង ។

**កងទ័ព** ឬ **កងទ័ពធំ** ឬ **កងទ័ពឈ្លូន** ៖ មានទាហានចំនួនមួយសែននាក់ មាន **មេបញ្ជាការកងទ័ព** ម្នាក់ជាអ្នកគ្រប់គ្រង ឬព្រះរាជាអង្គឯងតែម្តងជាមេបញ្ជាការ ។

### ១.៤. ទ័ពបិសាច

ក្នុងករណីខ្លះ ដោយទ័ពមនុស្សមានចំនួនមិនគ្រប់គ្រាន់ គេអាចពឹងពាក់ដល់ពួកទ័ពបិសាចអោយមកជួយយកអាសាបាន ។ រឿងនេះមានលក្ខណៈអស្ចារ្យបន្តិច ប៉ុន្តែរាជពង្សាវតារខ្មែរបានកត់ត្រាទុកមក ហើយមានលំនាំជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយយ៉ាងពិតប្រាកដ ។ យ៉ាងណាមិញ នៅគ.ស. ១៥១៦ ទ័ពខាង **ស្តេចកន** បានដេញតាមទ័ពព្រះ**ចន្ទរាជា** ហើយទៅឡោមព័ទ្ធបន្ទាយពោធិ៍សាត់អស់រយៈពេល ១២ខែ តែវាយលុកចូលពុំបានសោះ ។

គ្រានោះ **តាពេជ** បានធ្វើពលិកម្មបូជាជីវិតទៅកែនទ័ពបិសាចដោយលោតចូលទៅក្នុងរណ្តៅមួយដែលមានដោតសុទ្ធតែអាវុធស្រួចៗ ។

## ២. គ្រឿងសស្ត្រាវុធ និង យុទ្ធោបករណ៍

គេសង្កេតឃើញថាមានគ្រឿងសស្ត្រាវុធខ្លះជារបស់ស្តេចទ្រង់រាជ្យ ឬ របស់ស្តេចត្រាញ់ និងសស្ត្រាវុធខ្លះទៀតអាចប្រើជាទូទៅក្នុងកងទ័ព ៖

- **ព្រះខាន់រាជ្យ** ឬ **ព្រះខាន់ជ័យ** និង **ព្រះលំពែងជ័យ** (សូមមើលសេចក្តីអធិប្បាយ ត្រង់វគ្គនិយាយពីគ្រឿងសំរាប់រាជ្យ) ។
- **ព្រះខាន់រង** ឬ **ព្រះខាន់ជ័យស្រី** មានរូបតូចជាងព្រះខាន់រាជ្យ ។
- **ព្រះខាន់ស្តេចត្រាញ់** ដែលព្រះរាជាទ្រង់ប្រទានអោយស្តេចត្រាញ់គ្រាដែលចេញទៅឈរត្រួតត្រាស្រុក (បុរាណហៅថា នីស្រុក) ។
- **ធ្នូ** ជាអាវុធមួយសំរាប់ព្រះរាជាផង សំរាប់ប្រើទូទៅផង ។
- **ស្នា**
- **ខែល** ៖ មានលក្ខណៈប្រហែលគ្នានឹងលំពែង ប្លែកតែនៅគល់ដងមានភួ ។
- **ដាវ** វែង **ដាវ** ខ្លី ។
- **ផ្គាក់ ចម្បូក**

- **លំពែង ខ្លី  លំពែង** វែង ។

- **ដំបង**

- **ខែល**

- **ក្រវិស**

- **កាំភ្លើង** តូច **កាំភ្លើង** ធំ ជាអាវុធដែលច្រើនតែទិញពីពួកអឺរ៉ុបនៅស្រុកជ្វាម៉ាឡាយូ ។ ក្នុងដំណាក់ការចុងក្រោយនៃចម្បាំងរវាងព្រះ **ចន្ទរាជា** និង **ស្ដេចកន** គេឃើញទាំងសងខាង បានចាត់អោយទិញអាវុធធុននេះរាប់ពាន់ដើមយកមកប្រើ ។

ចំណែកឯយុទ្ធោបករណ៍ គេឃើញមាន :

- **អាវក្រោះ** : គឺអាវស្រោបដែក មានតែស្ដេចសឹក និងពួកមេទ័ព មេកងប្រើសំរាប់ការពារព្រួញ និងដាវលំពែង ។

- **អាវយ័ន្ត** : គឺអាវដៃខ្លីហើយមានគូរជាយ័ន្ត បញ្ចុះសាច់មន្តអាគម ។

- **យ័ន្តតេជៈ** ឬ **កន្សែងយ័ន្ត** : គឺជាសំពត់ ៤ជ្រុង ហើយមានបញ្ចុះមន្តអាគម ។

- **ទង់ជាតិ** : ទង់សំរាប់ជាតិខ្មែរ ។

- **ទង់មហារាជ** : ទង់សំរាប់ស្ដេចទ្រង់រាជ្យ ។

- **ទង់ជ័យ** : ទង់ប្រចាំកងទ័ព ។

- **ស្គរជ័យ** : ស្គរដែលប្រើក្នុងចម្បាំង វាយសំរាប់ប្រជុំពល និងសំរាប់ប្រកាសអោយរេហ៍ ពលដឹងថាមានជ័យជំនះហើយ ។

– **គងជ័យ** : សំរាប់ប្រើក្នុងក្បួនទ័ព ។

– **ភ្លេងស្គរជ្វា ឬ ខ្លុំខែក** ។ ក្នុង១វង់មានចំនួនស្គរ ២ស្រឡៃ ១ ។ ភ្លេងនេះគេលេងក្នុងពេលលើកទ័ពចេញទៅច្បាំងដើម្បីជាគ្រឿងសម្រើបចិត្តទាហាន ។

សេចក្ដីដកស្រង់ខាងក្រោមនេះ អាចបង្ហាញពីទិដ្ឋភាពក្នុងការរៀបចំក្បួនទ័ពចេញដំណើរ ការប្រើយានជំនិះ និងយុទ្ធោបករណ៍ផ្សេងៗ(24) ។

"ខណៈនោះ ស្ដេច (ព្រះធម្មរាជាទី ១) ទ្រង់គ្រឿងរាជវណារង្គយុទ្ធ ស្រេចហើយស្ដេចឡើងគង់ព្រះទីនាំងហត្ថី ចងគ្រឿងគជាហរណៈ បាំងនូវព្រះបរមស្វេតច្ឆត្រនើតឆាយ ដោយនូវអភិរម សែនត្វាន ទង់ជ័យប្រពៃរន្ទាលប្រាលផ្គោគ្រប់កងគជសារ អស្សាពាជីយោធីព្រៀងព្រម មកស្ថិតចាំស្ដេចនៅព្រះលានជ័យ ។ លុះបានពិជ័យឫកល្អហើយ ហោរាក៏គោះគងទូងស្គរ អ្នកមុខអ្នកការក៏ប្រគំរងំដោយនូវតូរ្យតន្ត្រី ភ្លែភ្លៀវលេងស្គរជ័យល្វាសល្វៃព្យូហៈ ទ័ពចេញចាកព្រះមហានគរទៅឧត្តរទិស " ។

## ៣. ចម្បាំង

### ៣.១. ប្រភេទចម្បាំង

ក្នុងសម័យកាលដែលលើកយកមកសិក្សានេះ គេសង្កេតឃើញមានចម្បាំង ៣ប្រភេទដូចតទៅនេះ:

***ចម្បាំងគ្នាឯងក្នុងស្រុក***

ចម្បាំងប្រភេទនេះ សុទ្ធតែបណ្តាលមកពីវិបត្តិក្នុងរាជវង្ស ។ ចម្បាំងរវាងព្រះ**ស្រីរាជា** **ស្រីសុរិយោទ័យ** **ស្រីធម្មរាជា** (១៤៧៥-១៤៨៥) និងចម្បាំងរវាង **ស្រីសុគន្ធបទ** **ស្តេចកន** **ចន្ទរាជា** (១៥០៩-១៥១២ រួច ១៥១៦-១៥២៥) សុទ្ធតែជាចម្បាំងគ្នាឯងក្នុងស្រុកទាំងអស់ ។

***ចម្បាំងរំដោះទឹកដី***

ចាប់ពី ស.វ.ទី ១៣ រៀងមក ខ្មែរយើងត្រូវបាត់បង់ទឹកដីចាប់ពីវាលទំនាបនៃ**ទន្លេមេណាម** រហូតមកដល់ព្រំប្រទល់ខេត្តបាត់ដំបង សៀមរាប ។ ចាប់តាំងពីរជ្ជកាលព្រះ **ស្រីរាជា** ដល់ រជ្ជកាលព្រះ **សត្ថាទី ១** ខ្មែរយើងតែងបានលើកទ័ពទៅវាយរំដោះយកអាណាខេត្តដែលត្រូវបាត់បង់ទៅក្នុងកណ្តាប់ដៃសៀមនោះបានមកវិញ ។

***ចម្បាំងការពារជាតិ***

ក្នុងករណីខ្លះ ជនជាតិជិតខាងមានសៀម លាវ បានលើកទ័ពចូលមកវាយខ្មែរក្នុងបំណងពង្រីកទឹកដីរបស់គេដោយគេយកលេសផ្សេងៗ ។ ដោយព្រះ **ចន្ទរាជា** ទ្រង់ប្រកែកមិនព្រមថ្វាយដំរីស ព្រះចៅសៀមបានលើកទ័ពចូលវាយខ្មែរពីរលើក លើកទី១នៅសៀមរាប លើកទី២នៅពោធិ៍សាត់ ។ ក្រោយមក ក្នុងរជ្ជកាលព្រះ **បរមរាជាទី ៤** ដោយប្រជល់ដំរីចាញ់ខ្មែរ ស្តេចលាវបានលើកទ័ពចូលវាយខ្មែរពីរលើក ។ ប៉ុន្តែទាំងទ័ពសៀម ទាំងទ័ពលាវ សុទ្ធតែត្រូវទទួលបរាជ័យថយទៅវិញទាំងអស់ ។

### ៣.២. យុទ្ធសាស្ត្រ និងកលយុទ្ធ

ជាទូទៅ គេសង្កេតឃើញថាទោះនៅក្នុងចម្បាំងប្រភេទណាក៏ដោយ សុទ្ធតែមានគោលដៅចម្បាំងតែមួយ គឺវាយដណ្តើមយកទឹកដី និងប្រជារាស្ត្រ ហើយប្រសិនបើវាយយកមិនបានទឹកដីទេក៏គេខិតខំកៀរយកអោយបានមនុស្សមកខាងគេដែរ ។ ដោយហេតុនោះហើយ ទើបយើងឃើញថា នៅក្នុងរង្វង់ព្រំដែនទឹកដីខ្មែរសព្វថ្ងៃនៅមានជនជាតិបរទេសខ្លះ ដែលរស់រានរហូតមកដូចជាជនជាតិ **តូមា** នៅប៉ៃលិនខេត្តបាត់ដំបង ជនជាតិ **លាវ** នៅបារាយណ៍ នៅបាភ្នំជាដើម ។

នៅក្នុងការធ្វើចម្បាំងទាំងបីប្រភេទដូចបានពោលរួចមកហើយនោះ ឃើញថាគេច្រើនតែច្បាំងដោយទល់មុខគ្នា គឺថាគូបដិបក្ខទាំងសងខាងលើកទ័ពធំទៅតទល់គ្នាលើសមរភូមិតែម្តង (guerre de front) ។ ចំណែកឯរបៀបវាយទ័ពលើកទៅប្រយុទ្ធនឹងខ្មាំងសត្រូវ គេឃើញមានរបៀបសំខាន់តែមួយដែលគេច្រើនប្រើមានដូចតទៅ :

- **ទ័ពមុខ** (le corps d'avant - garde)
- **ទ័ពស្តាំ** (le corps de droite)
- **ទ័ពឆ្វេង** (le corps de gauche)
- **ទ័ពហ្លួង ឬ ទ័ពធំនៅកណ្តាលគេ** (le corps principal)
- **ទ័ពក្រោយ** (le corps d'arrière - garde)

គួរគប្បីបញ្ជាក់ថា ក្នុងករណីខ្លះ **ទ័ពមុខ** និង **ទ័ពក្រោយ** ពុំឃើញមានផងទេ ប៉ុន្តែមានទ័ពដែលមានមុខងារពិសេសខ្លះគឺ **ទ័ពក្រវែល ទ័ពស្ទាក់ ទ័ពជន្ល ទ័ពបង្កប់** ។

- **ទ័ពក្រវែល** គឺពួកទាហានដែលគេអោយដើរល្បាត ដើម្បីឃ្លាំមើលចលនា និងសកម្មភាពរបស់ទ័ពសត្រូវ ។

- **ទ័ពស្ទាក់** គឺពួកទាហានដែលមានបេសកកម្មរារាំងកុំអោយទ័ពសត្រូវទាក់ទងគ្នាបាន ឬកុំអោយទ័ពសត្រូវផ្នែកណាមួយទៅជួយផ្នែកណាមួយទៀតបាន ។

- **ទ័ពជន្ល** គឺពួកទាហានដែលគេអោយទៅមុន សំរាប់ទាក់ទាញអោយទ័ពសត្រូវដេញតាម ។

- **ទ័ពបង្កប់** គឺពួកទាហានដែលគេបង្កប់ទុកក្នុងព្រៃមិនអោយសត្រូវដឹង មានបេសកកម្មងើបវាយផ្ចប់សត្រូវពីគ្រប់ទិសកាលណាពួកនេះធ្លាក់ក្នុងអន្ទាក់របស់គេ ។

ចំពោះចំនួនទាហានក្នុងប្រភេទទ័ពទាំងប៉ុន្មានដូចបានរៀបរាប់រួចមកហើយនោះឃើញថា មានចំនួនមិនស្មើគ្នាក្នុងកងទ័ពម្ខាងៗ ។ ចំនួននេះតែងតែផ្លាស់ប្តូរទៅតាមកាលៈទេសៈ គឺថាទៅតាមលទ្ធភាពដែលគូបដិបក្ខអាចកែនបានតិច ឬច្រើន ។ ជាទូទៅគេសង្កេតឃើញ **ទ័ពមុខ** ឬ **ទ័ពស្រួច** តែងមានចំនួនច្រើនជាង **ទ័ពស្តាំ** និង **ទ័ពឆ្វេង** ដែលមានស្មើគ្នា ។ ឯ**ទ័ពក្រោយ** មានចំនួនប្រហាក់ប្រហែលនឹង**ទ័ពស្តាំឆ្វេង**ដែរ ។ មានតែ **ទ័ពហ្លួង ឬ ទ័ពធំ** ទេដែលមានចំនួនទាហានច្រើនជាងគេ ។ ឯ **ទ័ពក្រវែល ទ័ពជន្ល ទ័ពបង្កប់** មានចំនួនទាហានប្រហែលៗ គ្នាហើយតិចជាងគេផង ។

ខាងក្រោមនេះជាឧទាហរណ៍មួយពីចំណាត់ទ័ពសំរាប់ចូលច្បាំង (25) :

- **ទ័ពមុខ** : ២០ ០០០នាក់
- **ទ័ពស្តាំ** : ១០ ០០០នាក់

- **ទ័ពឆ្វេង** : ១០ ០០០នាក់
- **ទ័ពស្តាំ** : ៤០ ០០០នាក់
- **ទ័ពចន្លប់** : ៥ ០០០នាក់

ក្នុងផ្នែកកលយុទ្ធ ជួនកាលគេធ្វើកលជាចាញ់ហើយបើសត្រូវដេញតាមទៅនោះច្បាស់ជាត្រូវពួក **ទ័ពចន្លប់** និង **ទ័ពស្ទាក់** ងើបឡើងវាយផ្ទប់យកឈ្នះជាមិនខាន ។

ក្នុងករណីដែលទ័ពម្ខាងៗប្រយុទ្ធហើយទន់ដៃជាងទ័ពម្ខាងទៀត នោះគេច្រើនថយចូលការពារខ្លួនក្នុងបន្ទាយ ដូចកាលទ័ពព្រះបាទ **ស្រីសុគន្ធបទ** ថយចូលក្នុងបន្ទាយស្ទឹងសែន ទ័ពព្រះ **ចន្ទរាជា** ថយចូលក្នុងបន្ទាយពោធិ៍សាត់ ទ័ព **ស្តេចកន** ថយចូលក្នុងបន្ទាយ ស្រឡប់ពិជ័យ ទ័ពព្រះ **ស្រីសុរិយោពណ៌** ថយចូលក្នុងបន្ទាយលង្វែក ។ ឯទ័ពម្ខាងទៀតក៏មកធ្វើការឡោមព័ទ្ធអស់ពេលជាច្រើនខែ ។ បន្ទាយនិមួយៗសុទ្ធតែមានសើនមានប៉មសំរាប់ការពារមាំណាស់ ឯទ័ពនៅខាងក្នុងសុទ្ធតែបានប្រមូលស្បៀងទុកបំរុងសំរាប់រស់នៅអោយបានយូរពេល ។ ម្ល៉ោះហើយ ទ័ពម្ខាងទៀតដែលធ្វើការឡោមព័ទ្ធនោះមិនងាយចូលវាយលុកយកបន្ទាយបានដោយងាយៗទេ ។ **ស្តេចកន** អោយទាហានធ្វើកលជាក្បត់រត់ចូលខាងព្រះបាទ **ស្រីសុគន្ធបទ** ហើយរកឱកាសល្អចូលលុកធ្វើគុតព្រះអង្គបាន ។ ពេលនោះទ័ពខាង **ស្តេចកន** ក៏វាយលុកចូលយកបានបន្ទាយទៅ ។ កាលទ័ពសៀមលើកទ័ពចូលព័ទ្ធបន្ទាយលង្វែកលើកទី១ វាមិនអាចវាយយកបន្ទាយនោះទេ ព្រោះមានរបងឫស្សីព័ទ្ធពីក្រៅក្រាស់ពេក ។ ដោយហេតុនោះ សៀមបានធ្វើកលបាញ់ប្រាក់ដួងចូលក្នុងរបងឫស្សីមុននឹងដកថយទៅវិញ ហើយបញ្ជូនចារបុរសអោយមកស៊ើបយកការណ៍អោយដឹងថា តើខ្មែរខ្លាំងពូកែដោយសារអ្វី ។ ក្រោយមកដោយខ្មែរយើងនាំគ្នាឆ្ការព្រៃឫស្សី ដើម្បីយកប្រាក់នោះរហូតដល់ធ្លុះធ្លាយអស់ទើបទ័ពសៀមអាចវាយលុកចូលយកបន្ទាយបាន ។ កាលដែលទ័ពព្រះ **ចន្ទរាជា** ទៅព័ទ្ធ **ស្តេចកន** នៅក្នុងបន្ទាយស្រឡប់ពិជ័យហើយយកមិនបាននោះ ព្រះអង្គទ្រង់ចាត់អោយប្រកាសថា ព្រះអង្គនឹងវាយបន្ទាយអោយទាល់តែបាន ហើយនៅពេលយកបានបន្ទាយនោះ ជនណាដែលនៅក្នុងបន្ទាយនឹងត្រូវដាក់អោយទៅជាអ្នកងារ ។ ម្យ៉ាងទៀត ខាងព្រះ **ចន្ទរាជា** បានឃោសនាថា ព្រះចៅសៀមបានបញ្ជូនកងទ័ពមួយមកអោយជួយព្រះ **ចន្ទរាជា** ទៀត ។ ពាក្យនេះធ្វើអោយមនុស្សនៅក្នុងបន្ទាយមានការភិតភ័យយ៉ាងខ្លាំង ។ នៅពេលយប់ **ព្រះចន្ទរាជា** ទ្រង់បានចាត់អោយដុតស្នោស្នួតនៅជុំវិញបន្ទាយ ។ មនុស្សនៅក្នុងបន្ទាយឃើញដូច្នោះរិតតែភិតភ័យខ្លាំងថែមទៀត ដោយនឹកស្មានថាភ្លើងទាំងនោះជាកន្លែងជំរុំរបស់កងទ័ពសៀមមែន ។ ម្ល៉ោះហើយទ័ពរបស់ **ស្តេចកន** ក៏នាំគ្នាពពាក់ពពូនរត់ចេញពីបន្ទាយ ដោយខ្លាចគេសម្លាប់ផង និងខ្លាចគេដាក់អោយទៅជាអ្នកងារផង ។ គឺដោយហេតុនោះហើយ ទើបព្រះ**ចន្ទរាជា** អាចយកបន្ទាយស្រឡប់ពិជ័យ និង ចាប់**ស្តេចកន** បាន (11) ។

### ៣.៣. សកម្មភាពចិត្តសាស្ត្រក្នុងពេលធ្វើចម្បាំង

ក្នុងពេលធ្វើចម្បាំង មេម្ខាងៗ តែងតែផ្តល់រង្វាន់ដល់សេនាទាហានដែលមានថ្វីដៃ ដើម្បីជាការលើកទឹកចិត្ត នៅពេលផ្អាកសង្គ្រាមម្តងៗតែងតែមានការប្រឡងថ្វីដៃ ហើយបើឈ្មោះណាបានជាសេនាទាហានហើយ យសសក្តិទ្រព្យសម្បត្តិជារង្វាន់មិនគ្រាន់តែបានត្រឹមឈ្មោះនោះទេ តែបានដល់គ្រួសារខ្លួនទៀត ។

នៅរដូវវស្សា គេច្រើនតែព្រមព្រៀងគ្នារំសាយកងទ័ពបើកអោយទាហានត្រឡប់ទៅជួបជុំប្រពន្ធកូនផង និងអោយមានឱកាសធ្វើស្រែចំការ យកស្បៀងចិញ្ចឹមគ្រួសារ និងចិញ្ចឹមកងទ័ពតទៅទៀត ។

ដើម្បីអោយអ្នកស្រុក និងកងទ័ពគូសត្រូវចូលខាងខ្លួន គេតែងតែឃោសនាបង្ហាញនូវលក្ខណៈត្រឹមត្រូវពេញច្បាប់ខាងគេ ហើយបង្ហាញពីលក្ខណៈមិនគាប់ប្រសើររបស់ពួកគូបដិបក្ខ ដូចខាងព្រះ **ចន្ទរាជា** តែងតែឃោសនាប្រាប់រាស្ត្រថាព្រះអង្គជាពូជពង្សក្សត្រ ចំណែកឯ **ស្តេចកន** ជាពលព្រះមនុស្សក្នុងវណ្ណៈថោកទាបជាដើម ។

នៅពេលលើកទ័ពទៅវាយត្រង់តំបន់ណាដែលម្ខាងទៀតធ្លាប់កាន់កាប់ គេតែងតែបញ្ជូនអ្នកមានវោហារថ្វីមាត់ អោយទៅនិយាយបញ្ចុះបញ្ចូលចៅហ្វាយស្រុក និងប្រជារាស្ត្រអោយចូលមកខាងខ្លួនគេជាមុនសិន ។

ក្នុងការធ្វើចម្បាំង គេតែងតែចេញបញ្ជាហាមប្រាមមិនអោយទាហានទៅរំលោភជិះជាន់ប្លន់យកទ្រព្យសម្បត្តិពីប្រជារាស្ត្រឡើយ ។ បើមានជនណាល្មើសច្បាប់ធ្វើអោយរាស្ត្រក្តៅក្រហាយ នោះនឹងត្រូវទទួលទណ្ឌកម្មរហូតដល់ត្រូវប្រហារជីវិត ។

ម្យ៉ាងទៀត ខាងស្តេចបានបញ្ជាអោយយករាជប្រកាសទៅបិទនៅតំបន់សត្រូវកាន់កាប់ ថាបើជនណាមានចិត្តស្មោះត្រង់ព្រមចុះចូលបំរើព្រះអង្គពីឥឡូវទៅ ព្រះអង្គនឹងលើកទោសអោយ តែបើផ្ទុយទៅវិញកាលណាស្រុករាបទាបហើយ ព្រះអង្គនឹងទុកជាក្បត់ហើយត្រូវទទួលទោសជាទម្ងន់ មានការដាក់អោយទៅជាអ្នកងារជាដើម ។

## ឃ. ជីវភាពសង្គម

### ១. ថ្នាក់សង្គម

ទោះបីខ្មែរបានទទួលឥទ្ធិពលពីឥណ្ឌាក្នុងការបែងចែកមនុស្សក្នុងសង្គមជាវណ្ណៈក៏ដោយក៏សង្គមខ្មែរពុំមានលក្ខណៈដូចសង្គមឥណ្ឌាបេះបិទទេ ។ យ៉ាងណាមិញក្នុងសង្គមឥណ្ឌាគេបានបែងចែកមនុស្សជា ៤វណ្ណៈគឺ :

- វណ្ណៈទី ១ ជាវណ្ណៈរបស់ពួក **ព្រាហ្មណ:**
- វណ្ណៈទី ២ ជាវណ្ណៈរបស់ពួក **ក្សត្រិយ:**
- វណ្ណៈទី ៣ ជាវណ្ណៈរបស់ពួក **វៃស្ស:**
- វណ្ណៈទី ៤ ជាវណ្ណៈរបស់ពួក **សូទ្រ:**

ចំណែកឯក្នុងសង្គមខ្មែរសម័យនោះ ពុំមានចែកជាវណ្ណៈទេតែចែកជា **ថ្នាក់**ទៅវិញ (classes sociales) ហើយមានទាំងអស់ ៥ថ្នាក់ដូចតទៅ :

### ១.១. រាជវង្សានុវង្ស

ផ្ទុយពីសង្គមឥណ្ឌា ក្នុងសង្គមខ្មែរគឺពួក ក្សត្រិយ: អ្នកគ្រប់គ្រងប្រទេសជាថ្នាក់សង្គមដែលខ្ពស់ជាងគេ ។ តំណែងធំៗ ទាំងប៉ុន្មាន ច្រើនតែបានពួក **ក្សត្រិយ:** ជាអ្នកកាន់កាប់ ។

### ១.២. ពួកមន្ត្រី

ពួកនេះមានឯកសិទ្ធិច្រើន ដូចជាមិនបាច់បង់ពន្ធ និងមិនបាច់បំពេញកិច្ចការសាធារណៈជាដើម ។ ពួកមន្ត្រីជាន់ខ្ពស់ និងពួកចៅហ្វាយស្រុកសុទ្ធតែបានព្រះរាជាតែងតាំងឡើង ហើយត្រូវធ្វើសច្ចាប្រណិធានថាស្មោះត្រង់បំរើព្រះអង្គជានិច្ច ។

### ១.៣. បព្វជិត

**ឆាគូ :** ទោះបីខ្មែរលែងកាន់សាសនាព្រាហ្មណ៍ទៀតហើយក៏ដោយ ក៏ព្រះមហាក្សត្រខ្មែរពុំបានបោះបង់ចោលទាំងស្រុងនូវប្រពៃណីខាងសាសនាព្រាហ្មណ៍ផងទេ ។ ដោយហេតុនោះហើយ ទើបគេឃើញនៅក្នុងព្រះបរមរាជវាំងនូវវត្តមានរបស់ពួក **ឆាគូ** ដែលជាកូនចៅរបស់ពួកព្រាហ្មណ៍បុរោហិតកាលពីសម័យមុនៗ មានសម័យអង្គរជាដើម ។ មានឯកសារខ្លះថាពួក **ឆាគូ** អាចឡើងសោយរាជ្យបាន

ក្នុងករណីណាដែលព្រះមហាក្សត្រសោយទិវង្គតទៅហើយគ្មានបុត្រ ឬញាតិណាអាចឡើងសោយរាជ្យស្នង (22) ប៉ុន្តែក្នុងភាពពិតជាក់ស្តែង គេពុំដែលប្រទះករណីបែបនេះសោះឡើយ ។

ពួក **បាគូ** មានឯកសិទ្ធិជាអ្នកថែរក្សា **គ្រឿងសំរាប់រាជ្យ** មាន **ព្រះខាន់រាជ្យ ព្រះលំពែងជ័យ** និង **គ្រឿងបញ្ចក្សេត្រ** និងជាអ្នកប្រារព្ធធ្វើរាជពិធីផ្សេងៗ ក្នុងព្រះបរមរាជវាំង ។ ម្យ៉ាងទៀត ពួក **បាគូ**នៅមានឯកសិទ្ធិមិនបាច់បង់ពន្ធ មិនបាច់បំពេញកិច្ចការសាធារណៈ និងមិនបាច់កែនធ្វើទាហានទៀតផង ។

**ព្រះសង្ឃ** : ជាថ្នាក់សង្គមមួយពិសេស ព្រោះចៅក្រមដែលជាគ្រហស្ថ ពុំអាចកាត់សេចក្តីចំពោះទោសកំហុសរបស់ **ព្រះសង្ឃ** បានឡើយ ។ មានតែ **ព្រះសង្ឃនាយក** ទើបអាចត្រួតពិនិត្យវិន័យ និងដាក់ទណ្ឌកម្មលើរូបព្រះសង្ឃបាន ។ ក្នុងករណីមានទោស ឬទោសឧក្រិដ្ឋ **ព្រះសង្ឃនាយក** អាចផ្សឹក **ព្រះសង្ឃ** ដែលមានទោសបានហើយបញ្ជូនខ្លួនទៅអោយតុលាការពិសេសកាត់ទោស ។ **ព្រះសង្ឃ** មានឯកសិទ្ធិដូចពួក **បាគូ** ដែរ ។

## ១.៤. អ្នកជា (ពួជព្រៃងារ)

គេអាចប្រៀបធៀបពួកនេះទៅនឹងពួក **វៃស្យះ** នៅក្នុងសង្គមឥណ្ឌា ។ ពួកនេះគេសំដៅយកប្រជារាស្ត្រទូទៅ ដែលប្រកបរបរស្រែចំការ លក់ដូរ នេសាទជាដើម ។

## ១.៥. ខ្ញុំ

គេអាចប្រៀបពួកនេះទៅនឹងពួក **ស្ទូទ្រះ** នៅក្នុងសង្គមឥណ្ឌា ។ មាន **ខ្ញុំ** បីប្រភេទ :

- **ខ្ញុំស្តេច** : ជនដែលធ្លាក់ខ្លួនទៅជាខ្ញុំស្តេច គឺពួកឈ្លើយសង្គ្រាម ជនប្រព្រឹត្តបទឧក្រិដ្ឋ ជនធានាអ្នកទោសឧក្រិដ្ឋដែលរត់រួច សម្លាប់គេ ធ្វើប្រាក់បន្លំ ដុតផ្ទះ ស្ត្រីដែលមានសហាយត្រូវប្តីសម្លាប់ និងកូនពួកខ្ញុំរបស់ស្តេច ។

ខ្ញុំប្រភេទនេះ គេនៅហៅថា **ពួកងារ** ដែលមានការបញ្ជាក់ពីឯកសារអក្សរសិល្ប៍ ។ យ៉ាងណាមិញ រឿង**ទុំទាវ** បានប្រាប់យើងថា អ្នកស្រុកត្បូងឃ្មុំដែលបណ្តោយអោយ **អរជូន** សម្លាប់ **ម៉ឺនងត**(ទុំ) ដែលមានព្រះរាជសារជាប់នៅនឹងខ្លួននោះសុទ្ធតែត្រូវដាក់អោយទៅជា **ពួកងារ** ទាំងអស់ ។ ម្យ៉ាងទៀតនៅពេលដែលព្រះ**ចន្ទរាជា**មានជ័យជំនះលើ **ស្តេចកន** បក្សពួករបស់ **ស្តេចកន** សុទ្ធតែត្រូវដាក់ជា **ពួកងារ**ទាំងអស់ដែរ ។

គួរគប្បីជ្រាបថា ពួកខ្ញុំប្រភេទនេះច្រើនតែត្រូវបង្ខំអោយធ្វើការជាទម្ងន់លើដីព្រះរាជទ្រព្យ ។ ក្នុងករណីខ្លះពួកនេះអាចរំដោះខ្លួនបាន ដោយសេចក្តីអនុគ្រោះរបស់ស្តេច ដោយលោះខ្លួនដោយប្រាក់ ដោយការជំនួស ដោយការសាងផ្នួស (22) ។

- **ខ្ញុំចក្ក** ៖ ខ្ញុំប្រភេទនេះនៅមានឈ្មោះម្យ៉ាងទៀតហៅថា **ពលព្រះ** ឬ **ពលព្រះរតន** ត្រៃ ។ រាជពង្សាវតារខ្មែរ (26) បាននិយាយថាពួកខ្ញុំប្រភេទនេះមានកំណើតកើតមកតាំងពីរជ្ជកាល ព្រះបាទ **ធម្មរាជាទី ១** ម្ល៉េះ ៖

"ស្ដេច (ព្រះបាទធម្មរាជា) គង់ក្នុងភេទជាភិក្ខុភាវៈ៣ថ្ងៃហើយទ្រង់លាចាកសិក្ខាបទ ។ ទ្រង់បរិច្ចាគព្រះរាជទ្រព្យធ្វើឆ្លោតព្រះរាជទានបណ្ដារាស្ត្រជាអនេកអនន្តពន់ពេក ។ ទ្រង់ព្រះរាជសទ្ធាវេរភូមិ ២១ ស្រែ ២១ ខ្ញុំប្រុស ២១ នាក់ ខ្ញុំស្រី ២១ នាក់ រទេះគោ ២១ នឹម រទេះក្របី ២១ នឹម សេះ ២១ ដំរី ២១ នូវគ្រឿងប្រគំផ្សេងៗថ្វាយទុកជាទាសាទាសីអោយរក្សាព្រះចេតិយ ព្រះវិហារសីមាសំរាប់បោសច្រាសសំអាត ។ ទ្រង់តាំងអោយមានមេពីរនាក់ជានាយត្រួតត្រារក្សា ។ អាស្រ័យហេតុនេះហើយបានជាមាន **ពលព្រះស្រីរតនត្រៃ** តាំងពីនោះរៀងមក" ។

គួរគប្បីជ្រាបថា ពួក **ពលព្រះ** នេះ ទោះបីមានបុណ្យសក្តិខ្ពង់ខ្ពស់យ៉ាងណាក៏ដោយ ក៏នៅតែពុំអាចរំដោះខ្លួនអោយចេញផុតពីឋានៈនេះបានឡើយ ។ ព្រះបាទ **ស្រីសុគន្ធបទ** ទ្រង់មានបំណងរំដោះព្រះស្នំឯក (នាង **ស**) និង **ស្តេចកន** ជាព្រះអនុជថ្លៃអោយរួចពីឋានៈ **ពលព្រះ** ។ ព្រះអង្គទ្រង់បានពិគ្រោះនឹងមន្ត្រីជាន់ខ្ពស់ តែមន្ត្រីទាំងនោះបានទូលវិញថា គ្រួសារណាមួយដែលធ្លាក់ខ្លួនទៅជា **ពលព្រះ** ហើយ ត្រូវស្ថិតនៅក្នុងឋានៈនោះអស់រយៈពេល ៥០០០ឆ្នាំ ហើយព្រះរាជាក៏ពុំអាចធ្វើការរំដោះបានដែរព្រោះបើព្រះអង្គហ៊ានប្រព្រឹត្តដូច្នោះ អ្នកផងនឹងចោទថាព្រះអង្គពុំគោរពចំពោះព្រះរតនត្រៃឡើយ (11) ។

ឯកសារខ្លះ (22) បានបញ្ជាក់ថា ឋានៈ **ពលព្រះ** នេះ គឺបានមកពី ៖

- ម្ដាយជា **ពលព្រះ**
- ធ្វើឃាតព្រះសង្ឃ
- លួចទ្រព្យគរុភ័ណ្ឌ
- ដុតវត្ត
- ទោសកំហុសខ្លះប្រព្រឹត្តដោយព្រះសង្ឃ ដូចជាសាហាយស្មន់ ងប់ក្នុងកាមគុណ ធ្វើថ្នាំពន្លូតកូន ។ល។

ពួកខ្ញុំប្រភេទនេះទំនងជាមានជីវភាពមិនយ៉ាប់យឺតដូចខ្ញុំប្រភេទដទៃទៀតទេ ព្រោះព្រះសង្ឃតែងមានព្រះទ័យសប្បុរសចំពោះពួកនេះ ។

**ខ្ញុំគេ** (ទាសៈ ទាសី) ពួកនេះគឺជាខ្ញុំកំដររបស់ពួកអ្នកជា ឬពួកមន្ត្រី ។ ឋានៈនេះ ត្រូវបានទៅជនណាដែលជំពាក់បំណុលគេហើយគ្មានប្រាក់សងវិញ បានទៅពួកឈ្លើយសង្គ្រាមឬពួកអ្នកស្រុកភ្នំដែលគេទៅចាប់យកមកដោយបង្ខំ ។ពួកខ្លះអាចរំដោះខ្លួនបានតែមានខ្លះមិនអាចរំដោះខ្លួនបានឡើយ ។

## ២. ការរស់នៅ និងសេដ្ឋកិច្ច

ការរស់នៅរបស់អាណាប្រជានុរាស្ត្រក្នុងគ្រាស្រុកមានសន្តិភាព និងក្នុងគ្រាស្រុកមានចម្បាំងរាំងជល់ ឃើញថាមានលក្ខណៈខុសប្លែកគ្នាឆ្ងាយណាស់ ។

សេចក្តីស្រង់ខាងក្រោមនេះពីសៀវភៅ " Le Sdach Kân" របស់លោក Adhémard Leclère អាចបញ្ជាក់ពីលក្ខណៈនេះបានខ្លះ :

" Le royaume avait retrouvé la paix d'autrefois et les habitants se disaient plus heureux sous le roi Kân qu'ils ne l'avaient jamais été sous les rois de l'ancienne monarchie" ។

ជាទូទៅ គេឃើញថាអាណាប្រជានុរាស្ត្រមានកាតព្វកិច្ចត្រូវ **បង់ពន្ធ** ជូនរាជការ ប៉ុន្តែក្នុងករណីខ្លះព្រះរាជាទ្រង់សព្វព្រះរាជហឫទ័យលើកលែងមិនយកពន្ធបាន ដូចព្រះ**ធម្មរាជា** ទ្រង់បានបញ្ជាអោយលើកលែងពន្ធរាជការខ្លួន និងពន្ធព្រះរាជធានី អស់រយៈកាល ៣ឆ្នាំ។ ចំណែកឯ ព្រះបាទ **ស្រីជេដ្ឋាធិរាជ** (ស្តេចកន) កាលច្បាំងឈ្នះព្រះបាទ **ស្រីសុគន្ធបទ** ហើយធ្វើពិធីរាជាភិសេកឡើងសោយរាជ្យនោះ ព្រះអង្គទ្រង់បង្គាប់អោយរាជការលើកលែងអាណាប្រជានុរាស្ត្រទូទាំងប្រទេសមិនអោយបង់ពន្ធក្នុងរយៈពេលមួយឆ្នាំ ហើយគេបានបញ្ជាក់សេចក្តីថាអាណាប្រជានុរាស្ត្របានសម្បូណ៌សប្បាយ (11) ។

ម្យ៉ាងទៀត អាណាប្រជានុរាស្ត្រតែងតែត្រូវកែនអោយ **បំពេញកិច្ចការធំៗ** ដូចជាលើកផ្លូវ សង់ស្ពាន ជីកព្រែក ជីកអូរ លើកទំនប់ ។ល។ សំរាប់បំរើប្រយោជន៍រួម និងកិច្ចការខ្លះទៀតសំរាប់បំរើផលប្រយោជន៍របស់ព្រះរាជា ។

ក្រៅពីកិច្ចការទាំងប៉ុន្មានដែលត្រូវបំពេញដូចបានរៀបរាប់រួចមកហើយនេះ ពួកយុវជនក្នុងព្រះរាជាណាចក្រត្រូវជាប់កំណែនជា **ទាហានក្រៅកំណែន** ទៀត ។ នៅពេលណាស្រុកមានចម្បាំង ពួកទាហានប្រភេទនេះត្រូវគេកែនអោយចូលបំរើក្នុងកងទ័ពភ្លាមៗ ។

ក្នុងករណីស្រុកកើតចម្បាំង ទោះជាចម្បាំងគ្នាឯងក្តី ចម្បាំងការពារជាតិក្តី អាណាប្រជានុរាស្ត្រត្រូវជួបប្រទះនឹងទុក្ខវេទនាយ៉ាងខ្លាំង ព្រោះក្រៅពីកាតព្វកិច្ចទាំងប៉ុន្មានដែលត្រូវបំពេញខាងលើ រាស្ត្រត្រូវប្រមូលទ្រព្យសម្បត្តិ ស្បៀងអាហារផ្គត់ផ្គង់អោយកងទ័ពថែមទៀត ។ ពិសេសទៅទៀតក្នុងចម្បាំងនៅសម័យណាក៏ដូចនៅសម័យណាដែរ អាណាប្រជានុរាស្ត្ររមែងតែងតែស្លាប់ដោយខ្មាំងសត្រូវប្រហារផង ដោយជម្ងឺតម្កាត់ផ្សេងៗផង ។ ឆ្លៀតឱកាសដែលមានការវឹកវរដូច្នោះ ចោរខ្មួញតែងតែកំរើកថ្លើមធំ ប្លន់កាប់ចាក់នៅគ្រប់ស្រុកគ្រប់តំបន់ ។

ក្នុងវិស័យសេដ្ឋកិច្ច គេសង្កេតឃើញមានសកម្មភាពផ្សេងៗ ដូចតទៅ :

**កសិកម្ម** : កសិកម្មទំនងជាសកម្មភាពសេដ្ឋកិច្ចសំខាន់ជាងគេ ព្រោះគេបានសង្កេតឃើញថាអ្នកដឹកនាំជាតិតែងតែយកចិត្តទុកដាក់នឹងបញ្ហាទឹកណាស់ ។ ក្នុងការស្ថាបនារាជធានីថ្មីម្តងៗ ព្រះរាជា

តែងនឹកគិតទៅដល់ដីធ្លីសំរាប់អោយរាស្ត្រធ្វើស្រែចំការនិងការជីកអូរ ជីកប្រឡាយ ជីកព្រែកសំរាប់យកទឹកផ្គត់ផ្គង់ដល់មុខរបរនេះទៀត ។ ក្នុងរជ្ជកាលរបស់ព្រះ **ចន្ទរាជា** ព្រះអង្គទ្រង់បានបញ្ជាអោយកាប់ឆ្ការព្រៃ ដើម្បីពង្រីកទំហំដីស្រែចំការ ។ ក្នុងគ្រាមានចម្បាំងគ្នាឯងក្នុងស្រុក តែកាលណាដល់រដូវវស្សាគេតែងតែស្រុះស្រួលគ្នាទាំងសងខាង ដើម្បីរំសាយទ័ពផ្អាកសង្គ្រាម អោយទាហានត្រឡប់ទៅកាន់ទីលំនៅរៀងខ្លួន និងប្រកបរបរស្រែចំការ ។ ធ្វើយ៉ាងនេះឃើញថា ដូនតាយើងលោកយល់ច្បាស់ណាស់នូវសារៈសំខាន់របស់សេដ្ឋកិច្ចក្នុងពេលចម្បាំងគឺ " **ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ** " ។ យ៉ាងណាមិញប្រសិនបើគ្មានបាយទេ ទាហាន និងអាណាប្រជានុរាស្ត្រទូទៅនឹងត្រូវដាច់ពោះស្លាប់ហើយគេក៏គ្មានលទ្ធភាពនឹងធ្វើចម្បាំងតទៅទៀតដែរ ។

ក្នុងសម័យលង្វែក គឺនៅពេលដែលព្រះរាជាខ្មែរបានទាក់ទងជាមួយអ្នកផ្សាយសាសនាព័រទុយក័ល និងអេស្ប៉ាញ ព្រះអង្គតែងបានផ្តល់ទេយ្យទានជាអង្ករដល់ពួកអ្នកទាំងនោះដែលរស់នៅក្នុងប្រទេសខ្មែរផង និងដល់អង្គការធំខាងផ្សាយសាសនានៅ Malacca ផង ។

**ពាណិជ្ជកម្ម** : ដោយសារទន្លេមេគង្គជាផ្លូវគមនាគមន៍មួយយ៉ាងសំខាន់ ក្រុងចតុមុខក៏ក្លាយទៅជាកំពង់ផែមួយដែលមានឈ្មួញបរទេសចេញចូលលក់ដូរតាំងពីរជ្ជកាល ព្រះ **បរមរាជាទី២ ចៅពញាយ៉ាត** ម្ល៉េះ ។ ដល់មកសម័យព្រះ **ចន្ទរាជា** និង **ស្តេចកន** ច្បាំងគ្នាឯង គេឃើញមេទាំងពីរនេះសុទ្ធតែបានបញ្ជាអោយជីកទំនិញយកទៅលក់ឯបរទេស ហើយទិញយកគ្រឿងសស្ត្រាវុធមកវិញ ។ តាមឯកសារអឺរ៉ុប (19) ព្រះ **បរមរាជាទី ៤** កាលដែលទាក់ទងជាមួយជនជាតិអឺរ៉ុបនោះ ព្រះអង្គទ្រង់មានសង្ឃឹមថាសកម្មភាពខាងជំនួញនឹងកើតមានឡើង បន្ទាប់ពីការមកដល់របស់ពួកបព្វជិត តែព្រះអង្គពុំបានទទួលផលល្អក្នុងវិស័យនេះឡើយ ។ក៏ប៉ុន្តែបើតាមប្រភពដដែលនោះ ឃើញថាក្នុងរជ្ជកាលក្រោយៗមកទៀតមានឈ្មួញបរទេសជាច្រើនគឺ ចិន ជប៉ុន ជ្វា បានមកធ្វើជំនួញក្នុងប្រទេសខ្មែរតាមផ្លូវទឹក ជាពិសេសនៅកំពង់ផែចតុមុខនេះឯង ដែលជាផ្សារលក់គ្រឿងទេស ភ្លុកដំរី ស្បែកសត្វ ជ័រកំញាន ។ល ។

**សិប្បកម្ម** និង **ឧស្សាហកម្ម** : ឧស្សាហកម្មដែលសំខាន់ជាងគេទំនងជាការស្លដែកនេះ ។ ឧស្សាហកម្មប្រភេទនេះ មានសន្ទុះខ្លាំងដោយមានការទំនុកបំរុង ពីព្រះ**ចន្ទរាជា** ។ ប៉ុន្តែរបរប្រើដែកជាវត្ថុធាតុដើម មានរបរដំដែកជាដើម ឃើញមានសកម្មភាពរួចទៅហើយ តាំងពីរជ្ជកាលព្រះបាទ **ចៅពញាយ៉ាត** ម្ល៉េះ ។

## ៣. ជំនឿ និងទំនៀមទំលាប់

ទោះបីនៅសម័យនោះ ព្រះពុទ្ធសាសនាបានជ្រួតជ្រាបចូលក្នុងសង្គមខ្មែរហើយក៏ដោយ ក៏ជនជាតិខ្មែរយើងពុំបានលះបង់ចោលនូវជំនឿដើមរបស់ខ្លួនឡើយ ។ យ៉ាងណាមិញ តាំងពីព្រះរាជាដល់

ប្រជារាស្ត្រតូចតាចគ្រប់ជាន់ថ្នាក់សុទ្ធតែជឿលើខ្មោចបិសាច អារក្ស អ្នកតា បង់បត់ ។ ល ។ រាជពង្សាវតារខ្មែរបាននិយាយថាកាលកសាងរាជធានីចតុមុខ ព្រះ **បរមរាជាទៅពញាយ៉ាត** ទ្រង់ចាត់អោយសាង **ខ្លាងមឿង** (អ្នកតាចាំស្រុក) មួយនៅខាងមុខ **វត្តឧណ្ណាលោម** និងរូបអ្នកតា បង់បត់ជាច្រើនកន្លែងទៀត ទុកជាទ្វារព្រះនគរ ជាបង្ការសឹកសង្គ្រាមពីប្រទេសជិតខាង ។ **តាពេជ** ដែលបានបូជាជីវិត ដើម្បីទៅកែនទ័ពបិសាច មកជួយអាសាព្រះ **ចន្ទរាជា** ក្នុងគ្រាច្បាំងជាមួយ **ស្តេចកន** នោះបានក្លាយទៅជា **អ្នកតា** ១រូប ដែលប្រជារាស្ត្រខ្មែរបានធ្វើពិធីគោរពបូជា ជារៀងរាល់ឆ្នាំ ។

ក្នុងវិស័យជំនឿលើខ្មោចនេះ គេជឿទៀតថា ដើម្បីកសាងទំនប់ទឹកឬព្រះវិហារអោយជាប់ល្អ គេត្រូវយកអ្នកទោសអស់ជីវិតទៅកប់ក្រោមទំនប់នោះ ឬគេត្រូវយកខ្មោចទៅទ្រាប់បាតសសរព្រះវិហារ ។

ម្យ៉ាងទៀត ខ្មែរនៅគ្រប់ជាន់ថ្នាក់សុទ្ធតែយល់ថា ការយល់សប្តិជាការប្រាប់អោយដឹងមុនពីហេតុការណ៍ដែលបំរុងនឹងកើតឡើង ម៉្លោះហើយគេតែងតែអោយហោរទស្សន៍ទាយមើលមិនដែលខាន ជាពិសេសក្នុងមជ្ឈដ្ឋានបរមរាជវាំងដែលពួកហោរាជាមន្ត្រីមួយប្រភេទចាំតែបំពេញមុខការខាងទស្សន៍ទាយនេះឯង ។

ក្រៅពីនេះ ខ្មែរនៅមានជំនឿមាំលើពាក្យសម្បថដែលគេយល់ថា មានលក្ខណៈសក្តិសិទ្ធិណាស់ ។ ពួកនាម៉ឺនសព្វមុខមន្ត្រី ពួកសេនាទាហានសុទ្ធតែត្រូវផឹកទឹកពិភទ្ធសច្ចាជារៀងរាល់ឆ្នាំ ជាការសំដែងភក្តីភាពរបស់ខ្លួនចំពោះព្រះមហាក្សត្រ ។

រាជពង្សាវតារខ្មែរបានកត់ទុកនូវពិធីជាទំនៀមទំលាប់យ៉ាងសំខាន់ពីរ គឺពិធី **បុណ្យចូលឆ្នាំថ្មី ១** និងពិធី **បុណ្យអុំទូក ១** ។

**បុណ្យចូលឆ្នាំថ្មី** ទំនងជាពិធីបុណ្យសំខាន់ជាងគេ ពីព្រោះទោះបីមានកើតចម្បាំងគ្នាឯងក៏ដោយក៏គេត្រូវផ្អាកចម្បាំងនោះសិនដើម្បីបានរៀបចំពិធីបុណ្យនោះ ។ ឯពិធី **បុណ្យអុំទូក** ជាឱកាសមួយដែលគេធ្វើការប្រណាំងទូក លយកន្ទោងធំ ទូកប្រទីប និងអុជកាំជ្រួច ។ គេថាធ្វើដូច្នេះ គឺដើម្បីថ្វាយទៅព្រះចង្កូមកែវដែលតំកល់នៅពិភពនាគ ឯការអុជកាំជ្រួចរន្ទាគឺថ្វាយទៅចូឡាមណីចេតិយ ដែលតំកល់ព្រះចង្កូមកែវនៅស្ថានត្រៃត្រិង្ស (27) ។

## ខ. វប្បធម៌

### ១. អក្សរ - ភាសា - អក្សរសិល្ប៍

គួរគប្បីរំលឹកឡើងវិញថា ចាប់តាំងពីដើមស.វ.ទី ១៤ រៀងមក គេពុំឃើញមានសិលាចារឹកនៅប្រទេសខ្មែរទៀតទេ ។ លុះដល់មករជ្ជកាលរបស់ព្រះ **ចន្ទរាជា** ទោះបីពេលនោះរាជធានីពិតប្រាកដ

តាំងនៅក្រុងលង្វែកក៏ដោយ ក៏ព្រះរាជាខ្មែរតែងនិយមនាំពួកបរិវារទៅគង់នៅតំបន់អង្គរជាហូរហែរ រៀងមក ។ គឺក្នុងសម័យនោះហើយដែលខ្មែរបានកសាងសិលាចារឹកឡើងវិញ ។ សិលាចារឹកទាំងនោះ គេបានចារទុកនៅប្រាសាទ **នគរវត្ត** ជា៣អន្លើ គឺនៅទីដែលហៅថា **ព្រះពាន់** ត្រង់ដែលមានព្រះពុទ្ធរូបច្រើននោះខ្លះ នៅថ្នាក់លើបំផុតដែលហៅថា **បាកាណ** នោះខ្លះ និងនៅ **ព្រះរបៀង** ថ្នាក់ក្រោម ។ សិលាចារឹកទាំងនោះមានទាំងអស់ ៤០ផ្ទាំង មានចុះកាលកំណត់ពី**គ.ស. ១៥៦៥ ដល់ ១៧៤៦** ប៉ុន្តែសករាជដែលប្រើគឺជា **មហាសករាជ** ។ សេចក្តីក្នុងសិលាចារឹកនោះនិយាយពីរឿងធ្វើបុណ្យផ្សេងៗ គឺប្រោសខ្ញុំអោយរួចជាអ្នកជា បំបួសមនុស្ស លាបំណន់ សាងព្រះ សាងពិតាន និងថ្វាយរបស់ជាពុទ្ធបូជា ។ល ។ ជារបស់ស្តេចខ្លះ មន្ត្រីខ្លះ រាស្ត្រខ្លះ (28) ។

ចំពោះសេចក្តីក្នុងសិលាចារឹកទាំងនោះ អ្នកស្រាវជ្រាវខ្មែរមួយក្រុមបានបន្ថែមសេចក្តីទៀតថា "សេចក្តីអស់នេះ ជាពាក្យរបស់**អ្នកចាលចាញ់** ហើយមានទីពឹងទីរលឹកចំពោះព្រះរតនត្រ័យប៉ុណ្ណោះ ជាអ្នកសុខចិត្តទទួលសេចក្តីលំបាកវេទនាដោយយល់ថាជាផលនៃកម្មអាក្រក់ដែលខ្លួនបានប្រព្រឹត្តមក ហើយក្នុងអតីតជាតិ តែពុំបានអស់កម្លាំងសេចក្តីប្រឹងប្រែងឡើយ តែងខំសន្សំបុណ្យកុសលដើម្បីសេចក្តីចំរើនដែលខ្លួន និងដល់ប្រទេស " (29) ។

ភាសាដែលប្រើក្នុងសិលាចារឹកទាំងនោះ ជាភាសាខ្មែរធម្មតាក្នុងសម័យកណ្តាល មានពាក្យពេចន៍បុរាណលាយឡំខ្លះដែរ តែយើងអាចមើលយល់សេចក្តីបានច្រើន ។

ជាការគួរអោយស្តាយពេកណាស់ **សាស្ត្រាស្លឹករិត** និង **ក្រាំង** ក្នុងសម័យដែលយើងលើកយកមកសិក្សានេះត្រូវវិនាសបាត់បង់ខ្ទេចខ្ទីអស់ជាច្រើន នេះទំនងជាមកពីសត្រូវជិតខាងកាលដែលចូលមកលុកលុយស្រុកទេសយើង គេនាំគ្នាដឹកជញ្ជូនយកទៅទុកជាទ្រព្យសម្បត្តិផ្ទាល់ទៅ ហើយម្យ៉ាងទៀតប្រហែលជាត្រូវភ្លើងឆេះក្នុងគ្រាមានសង្គ្រាមនោះហើយ ។ ប្រសិនបើមាននៅសេសសល់ គឺនៅតាមវត្តអារាម តែច្រើនពុំមានឈ្មោះអ្នកនិពន្ធ ។ ចំពោះរឿងនេះមានមតិខ្លះយល់ថា មកតែពីរបបគ្រប់គ្រងធ្វើអោយអ្នកនិពន្ធខ្លាចរអាពុំហ៊ានបញ្ចេញឈ្មោះរបស់ខ្លួនអោយអ្នកផងដឹងស្គាល់ទេ តែមានមតិខ្លះទៀតយល់ថា មកពីអ្នកចារមានទំលាប់អាក្រក់លប់បំបាត់ឈ្មោះអ្នកនិពន្ធចោល ហើយតាំងខ្លួនឯងជាអ្នកនិពន្ធជំនួសទៅវិញ ។

ស្នាដៃមួយដែលគេស្គាល់ឈ្មោះអ្នកនិពន្ធពិតប្រាកដគឺ **ល្បើកអង្គរ** និពន្ធដោយ**អ្នកឪង** ក្នុង គ.ស.១៥៩៨ ជាកាព្យនិយាយពីការកសាងប្រាសាទ **អង្គរវត្ត** តាមរបៀបរឿងទេពនិទាន ។ ប៉ុន្តែអ្នកស្រាវជ្រាវខ្មែរខ្លះបានដាក់កាលកំណត់រឿងនេះខិតមកមុខបន្តិចទៀត គឺនៅគ.ស.១៦០៩ វិញ (30) ។

## ២. សាសនា និងលទ្ធិផ្សេងៗ

### ២.១. ព្រះពុទ្ធសាសនា

ព្រះពុទ្ធសាសនាបែបហីនយានប្រើភាសាបាលីដែលបានចូលមកប្រតិស្ឋានក្នុងប្រទេសចាប់តាំងពីបដិវត្តន៍នាយត្រសក់ផ្អែម បានចាក់រឹសគល់យ៉ាងជ្រៅចូលក្នុងសង្គមខ្មែរ ជនជាតិខ្មែរគ្រប់ស្រទាប់ ចាប់តាំងពីព្រះមហាក្សត្រដល់ប្រជារាស្ត្រតូចតាចបំផុតសុទ្ធតែមានជំនឿមុតមាំលើព្រះពុទ្ធសាសនាដែលគេបានចាត់ទុកថាជាទីពឹងទីរលឹក ទោះបីគេបានលះបង់ចោលជំនឿដើមរបស់គេលើខ្មោច បិសាច អារក្ស អ្នកតា បង់បត់ក៏ដោយ ។ សង្គមខ្មែរលែងងាកទៅរកសាសនាព្រាហ្មណ៍ទៀតហើយ ។ ប៉ុន្តែនៅព្រះបរមរាជវាំង គេឃើញមានពួក **បាគូ** (ព្រាហ្មណ៍) ដែលគ្រាន់តែមាននាទីថែរក្សាព្រះ **ខាន់រាជ្យ** ព្រះ **លំពែងជ័យ** និង **គ្រឿងបញ្ចក្សេត្រ** និងរៀបចំធ្វើព្រះរាជពិធីផ្សេងៗតែប៉ុណ្ណោះ ។

ក្នុងសម័យនោះ ចំនួនវត្តអារាមបានកើនឡើងជាលំដាប់ ។ ព្រះ **មហាថេរ** ដែលមាននាទីមើលការខុសត្រូវលើការរៀបចំខាងសាសនា និងលើវត្តអារាមនៅក្នុងខេត្តនីមួយៗលែងមានលទ្ធភាពបន្តការគ្រប់គ្រងនោះតទៅទៀតហើយ ។ ដោយហេតុនោះ **សម្តេចព្រះសង្ឃរាជ** ដោយមានការព្រមព្រៀងជាមួយ **រាជាគណៈ ឋានានុក្រម** និងសហការីទាំងអស់ ទ្រង់បានស្នើទៅព្រះរាជា សូមអោយមានការកែប្រែដែលមានបែបផែនដូចតទៅ :

ព្រះមហាថេរមួយអង្គៗ ពីមុន ឥឡូវត្រូវតែងតាំងជា **មេគណៈ** ទទួលការខុសត្រូវលើគណៈសង្ឃក្នុងខេត្តនីមួយៗ ។ ចំណែកឯ **រាជាគណៈ** ទាំង៤សំរាប់ និង**សម្តេចព្រះសង្ឃរាជ** ជាអ្នកត្រួតពិនិត្យ និងសំរេចកិច្ចការសាសនាទាំងពួងក្នុងព្រះរាជណាចក្រទាំងមូល (31) ។

គួរគប្បីបញ្ជាក់ថា **រាជាគណៈ** ឬមន្ត្រីសង្ឃទាំង ៤ សំរាប់ ត្រូវចែកជា សំរាប់ឯក ទោ ត្រី ចត្វា ដូចមន្ត្រីជាន់ខ្ពស់ខាងអាណាចក្រដែរ :

- សំរាប់ឯក ជារាជាគណៈ របស់ក្សត្រិយ៍ទ្រង់រាជ្យ
- សំរាប់ទោ ជារាជាគណៈរបស់ក្សត្រិយ៍ឧភយោរាជ
- សំរាប់ត្រី ជារាជាគណៈរបស់សម្តេចព្រះមហាឧបរាជ
- សំរាប់ចត្វា ជារាជាគណៈរបស់សម្តេចព្រះវររាជជននី ។

គួរគប្បីបញ្ជាក់ម្យ៉ាងទៀតថា ព្រះសង្ឃ និងវត្តអារាមក្នុងសម័យនោះមានមុខងារយ៉ាងសំខាន់ក្នុងវិស័យសង្គមកិច្ច ។ យ៉ាងណាមិញ ព្រះសង្ឃពុំមែនគ្រាន់តែជាស្រែបុណ្យប៉ុណ្ណោះទេ តែព្រះអង្គជាអ្នកអប់រំ ផ្តល់ចំណេះវិជ្ជាគ្រប់បែបយ៉ាង គិតទាំងចំណេះខាងមុខរបរផងដល់ពុទ្ធបរិស័ទជើងវត្ត ។ នេះហើយជាកត្តាមួយធ្វើអោយរាស្ត្រខ្មែរកាន់តែជក់ចិត្តលើព្រះពុទ្ធសាសនាថែមទៀត ។ ពួកយុវជនតែង

និយមចូលទៅបួសអស់មួយរយៈកាលហើយសឹកមកវិញ ទើបអ្នកផងគេចាត់ទុកជាមនុស្សពេញលក្ខណៈមានចំណេះចេះដឹង ស្គាល់ខុស ស្គាល់ត្រូវ ។ ល ។

## ២.២. សាសនាគ្រិស្ត

ជនជាតិអឺរ៉ុបមានពួកព័រទុយក័ល និងអេស្ប៉ាញជាដើមបានប៉ុនប៉ងយកសាសនាគ្រិស្តមកផ្សាយក្នុងប្រទេសខ្មែរចាប់ពីពាក់កណ្តាលទី ២ នៃស.វ.ទី ១៦ ។ ទោះបីព្រះរាជាខ្មែរភាគច្រើនទ្រង់បានទទួលរាក់ទាក់ និងផ្តល់ជំនួយផ្សេងៗ ជាច្រើនដល់អ្នកផ្សាយសាសនា ក្នុងបំណងអោយពួកបព្វជិតជួយធ្វើអន្តរាគមន៍សុំជំនួយទ័ពមកទប់ទល់នឹងសត្រូវខាងក្នុង និងខាងក្រៅប្រទេសក៏ដោយ ក៏ការប៉ុនប៉ងផ្សាយសាសនាថ្មីនេះតែងទទួលបរាជ័យគ្រប់ពេលវេលា ។

បព្វជិត Gaspar da Cruz ដែលជាអ្នកផ្សាយសាសនាជាតិអឺរ៉ុបទី១ នៅប្រទេសខ្មែរបានទទួលសារភាពថាមានខ្មែរតែម្នាក់គត់ (?) ដែលបានចូលសាសនាគ្រិស្ត ហើយជននោះបានទទួលមរណភាពហើយទៅទៀត ។ បព្វជិតអង្គនេះបានបញ្ជាក់បន្ថែមទៀតថា ក្រោយមកពួកអ្នកផ្សាយសាសនាជាតិអឺរ៉ុបមានទំនាស់ជាមួយពួកព្រាហ្មណ៍នៅក្នុងវាំង ។ ខ្លួនលោកផ្ទាល់ក៏បានធ្វើអោយពួកព្រាហ្មណ៍អាក់អន់ចិត្ត ដោយលោកបានពន្យល់ដល់ប្រជារាស្ត្រថា "ព្រះអាទិទេពរបស់ពួកនេះពុំបានបង្កើតមេឃ និងដីទេហើយអាទិទេពនោះជាមនុស្សកាចសាហាវ និងជាអ្នកធ្វើបាបកម្មទៀតផង" ។ បព្វជិត Caçega បានកត់ទុកថា បព្វជិត Sylvestre បានលាងបាបអោយបានតែពួកអ្នកទោស និងជនបរទេស មានចិន ជប៉ុន ជ្វា តែគ្មានខ្មែរម្នាក់សោះ ។

គេសង្កេតឃើញថា ការប៉ុនប៉ងបង្កើតអង្គការដោយសាសនាគ្រិស្តនៅប្រទេសខ្មែរ ត្រូវបានទទួលបរាជ័យជាបន្តបន្ទាប់គ្នាគឺ :

- ការប៉ុនប៉ងទី ១ នៅក្នុងរជ្ជកាលព្រះ **សត្ថាទី ១**
- ការប៉ុនប៉ងទី ២ នៅក្នុងរជ្ជកាលព្រះ **រាមជើងព្រៃ**
- ការប៉ុនប៉ងទី ៣ នៅក្នុងរជ្ជកាលព្រះ **បរមរាជាទី ៥ ចៅពញាតន់**
- ការប៉ុនប៉ងទី ៤ នៅក្នុងរជ្ជកាលព្រះ **កែវហ្វាចៅពញាញោម** (19) ។

## ២.៣. លទ្ធិបុគ្គលនិយម

នៅសម័យអង្គរ យើងបានឃើញថា ចាប់តាំងពីស.វ.ទី ៩ ដល់ ស.វ.ទី ១២ គេមានភស្តុតាងជាច្រើនដែលបង្ហាញថា ព្រះរាជាខ្មែរបានកាន់លទ្ធិបុគ្គលនិយមស្របពេលជាមួយនិងលទ្ធិទេវរាជ ។ នៅសម័យដែលយើងលើកយកមកសិក្សានេះ រាជពង្សាវតារផ្តល់ភស្តុតាងថា លទ្ធិនេះនៅតែមានសកម្ម

ភាពបន្តទៅទៀត ។ ប្រភពនេះបានអោយពត៌មានថាព្រះ **ចន្ទរាជា** បានសាងព្រះវិហារមួយនៅក្នុងខេត្តវលាឡៀរ រួច "ទ្រង់ត្រាស់អោយសាងព្រះពុទ្ធរូបឈើសួងព្រះអង្គមួយព្រះអង្គ កំពស់ស្មើព្រះអង្គទ្រង់សណ្ឋិតកណ្តាល ។ ទ្រង់អោយសាងព្រះពុទ្ធរូបឈើមួយព្រះអង្គទៀត សួងព្រះអគ្គមហេសីព្រះ**តគចតី ស្រីធាចធីតា** កំពស់ស្មើព្រះអង្គសណ្ឋិតម្ខាង ទ្រង់សាងព្រះពុទ្ធឈើមួយព្រះអង្គទៀត សួងព្រះអង្គ**សម្តេចព្រះស្រីទេវីក្សត្រី** ជាសម្តេចព្រះរាជបុត្រី កំពស់ស្មើព្រះអង្គសណ្ឋិតម្ខាងទៀត " (39) ។

ប្រភពរាជពង្សាវតារខ្មែរ បាននិយាយទៀតថា កាលដែល **សម្តេចចៅហ្វាជុំខជំនាចទេវីនារីសោត័ណវៃ** ដែលត្រូវជាបិតាមាតាសម្តេចព្រះអគ្គមហេសី **ស្រីទេពធីតា ព្រះចរមរាជាទី ៤** "ទ្រង់ត្រាស់បង្គាប់អោយជាងយកថ្មល្អិតល្អ មកសាងជារូប **សម្តេចចៅហ្វាជុំខ១ ជំនាចទេវីនារីសោត័ណវៃ ១** តំកល់រូបទាំង ២ នោះក្នុងសាលាមួយទុកអោយសម្តេចព្រះអគ្គមហេសីគោរពរៀងមក" (33) ។

## ៣. សិល្បៈ

សិល្បៈខ្មែរច្រើនមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងសាសនា ។ ដោយហេតុថា នៅសម័យនោះខ្មែរមានជំនឿស៊ប់តែទៅលើព្រះពុទ្ធសាសនា សិល្បៈខ្មែរក៏មានលក្ខណៈទោរទន់ទៅតាមសាសនានោះដែរ ។

សេចក្តីដកស្រង់តទៅនេះ អាចបង្ហាញអោយឃើញនូវប្រធាន និងបច្ចេកទេសប្រើក្នុងវិស័យសិល្បៈស្ថាបត្យកម្ម និងចម្លាក់ក្នុងសម័យនោះ :

"អស់មុខមន្ត្រី មេការទាំងឡាយ កែនកូនជាងសាងព្រះមហាស្តូប ព្រះចេតិយធំនិងព្រះចេតិយតូចជាបរិវារ រចនាដោយថ្ម តកំផែងខ្វាត់ខ្វែង អោយជាច្រើនបែបច្រើនយ៉ាង សាងព្រះវិហារមានត្រីសូល៍កំពូលប្រាំ តាមកំផែង និងព្រះលានព្រះអារាមនោះ សឹងឆ្លាក់ឆ្លៅជាភាពមនុស្ស គ្រុឌនាគ សត្វមហិង្សា គោក្របី និងក្បាច់ភ្ញីផ្កា វល្លិ រចនាថ្ងៃថ្លា ប្រពៃ ហើយសាងព្រះពុទ្ធរូបបន្ទំ និងសណ្ឋិតជាច្រើនអង្គ មានសីមា និងរបៀបរោងទង ក្លោងទ្វារកំពូលមុខព្រហ្មសុទ្ធសឹងឆ្លាក់ឆ្លៅដោយថ្ម កកំផែងខ្វាត់ខ្វែង ជុំវិញសឹងថ្មបាយអ ថ្មគ្រោមក្រាលថ្មល្អិត ហើយមានរូបសិង្ហតោរាជសីហ៍ ដំរីយក្សដាក់គ្រប់ទ្វារ " (34) ។

ក្នុងវិស័យសិល្បៈដដែលនេះនាងកញ្ញា Madeleine Giteau បានចាប់អារម្មណ៍យ៉ាងខ្លាំងលើព្រះពុទ្ធរូបទ្រង់គ្រឿងឆ្លាក់ពីឈើ ឬពីថ្មដែលមានតំកល់នៅក្នុងប្រាសាទអង្គរវត្តសព្វថ្ងៃ ។ នាងយល់ថា ព្រះពុទ្ធរូបទាំងនោះអាចបង្ហាញអោយឃើញនូវរចនាបថទាំងឡាយនៃសិល្បៈខ្មែរក្នុងសម័យក្រោយអង្គរ (35) ។

# បញ្ជីឯកសារពិគ្រោះ


1. Henri Marchal, Angkor, Paris, 1955

2. Revue France-Asie, nº spécial pour la civilisation khmère, Saigon, 1955

3. ឯកសារមហាបុរសខ្មែរលេខ៤ បោះពុម្ពផ្សាយដោយលោកអេងសុតនៅភ្នំពេញគ.ស.១៩៦៩

4. លោកកងគីរី-លោកសែមសូរ : ប្រជុំអនុពាក្យទំនើប ទំព័រ ៨៤ -កំពង់ចាម-១៩៦៣ ។

5. សម្តេចព្រះមហាសុមេធាធិបតី ជួនណាត-ប្រវត្តិនៃវត្តឧណ្ណាលោម-ភ្នំពេញ គ.ស.១៩៥៣ ។

6. លោកស៊ឹមវ៉ា និងលោកលីអេង - ប្រវត្តិនៃប្រទេសកម្ពុជា (សាកល្បង) បោះពុម្ពហើយ តែមិនបានផ្សាយនៅភ្នំពេញ គ.ស.១៩៦៩ ។

7. Etienne Aymonier, Le Cambodge , tome III, Paris, 1904.

8. បែបរៀនសង្គមសិក្សា វិជ្ជាប្រវត្តិសាស្ត្រថ្នាក់មធ្យមសិក្សាឆ្នាំទី១ របស់ក្រុមវិជ្ជាការក្រសួងសិក្សាធិការ (ភាសាថៃ) បឹងកក -ព.ស. ២៥១២ គ.ស.១៩៦៨ ។

9. Dauphin Meunier, Histoire du Cambodge, PUF , Que sais -je ? Paris 1961.

10. -12- Henri Russier, Histoire sommaire du royaume du Cambodge des origines à nos jours (brochure ronéotypée), 1929 ?

11. Adhémard Leclère, le Sdach Kân, Imprimerie coloniale, Saigon, 1911.

13. Lê Thanh Khôi, Histoire de l'Asie du Sud - est, PUF , Que sais-je ? Paris, 1959.

14. B.P. Groslier, Angkor et le Cambodge au 16º siècle d'après les sources portugaises et espagnoles, Paris, 1958.

15. France- Asie, nº spécial 118-119, Présence du Royaume lao, Saigon. 1956.

16. ពង្សាវតារប្រទេសលាវ គឺក្រុងហ្លួងព្រះបាង ក្រុងវៀងចន្ទ ក្រុងជួន និងក្រុងចំប៉ាស័ក (ជាភាសាលាវ) - វៀងចន្ទ គ.ស.១៩៦៧ ។ Annales de Laos-Luang Prabang- Vientiane - Tranninh et Bassac, publiées la 22e année du règne de S.M. Sisavang Vong Roi du Luang Prabang, 1926.

17. ឯកសារមហាបុរសខ្មែរ លេខ២៧-២៨ របស់លោកអេងសុត បោះពុម្ពផ្សាយនៅក្រុងភ្នំពេញ នៅគ.ស.១៩៦៩ ។

18. ប្រវត្តិវិទ្យា ភាគ ១ ថ្នាក់ទី ១ - ខេមរយានកម្ម - ភ្នំពេញ - ១៩៧២ ។

19. Lawrence Palmer Priggs, Les missionnaires portugais et espagnols au Cambodge (1555-1603), texte traduit de l'anglais par Monique Dupont et publié dans Fullectin de la Société des Etudes Indochinoises (Nouvelle série - Tome xxv, n° 1-1er trimestre 1950), Saigon, 1950.

20. H. Sutton, Singapore in history, federal publications, Singapore, 1967.

21. ព្រះរាជពិធីទ្វាទសមាស ភាគ ១ បោះពុម្ពលើកទី ២ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ព.ស. ២៥០០ - គ.ស. ១៩៥៦ ។

22. J. Imbert, Histoire des Institutions Khmères, volume II, Annales de la Faculté de Droit de Phnom Penh, 1961.

23. លោកអនុសេនីយឯក សឺននី - ប្រវត្តិយោធាខ្មែរ អត្ថបទផ្សាយតាមទូរទស្សន៍សាធារណរដ្ឋខ្មែរ ខែ មេសា ១៩៧៤ ។

24. ឯកសារមហាបុរសខ្មែរ របស់លោក អេងសុត - លេខ ៦ - ភ្នំពេញ ១៩៦៩ ។

25. ឯកសារមហាបុរសខ្មែរ របស់លោក អេងសុត-លេខ ១២-១៦-១៨ ភ្នំពេញ ១៩៦៩ ។

26. ឯកសារមហាបុរសខ្មែរ របស់លោក អេងសុត - លេខ ៧ - ភ្នំពេញ គ.ស. ១៩៦៩ ។

27. ឯកសារមហាបុរសខ្មែរ របស់លោក អេងសុត - លេខ ១៥ - ភ្នំពេញ គ.ស. ១៩៦៩ ។

28. សិលាចារឹកនគរវត្ត និងបទានុក្រម - ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ គ.ស. ១៩៥៨ ។

29. គោលប្រវត្តិសាស្រ្តនៃអក្សរសាស្រ្តខ្មែរ ដោយប្រជុំសាស្រ្តាចារ្យ-ការផ្សាយរបស់បណ្ណាគារភ្នំពេញ - ភ្នំពេញ គ.ស. ១៩៥៦ ។

30. លោក ឃួន សុខម្ភូ - គំនិតរិះគន់សង្គមក្នុងអក្សរសិល្ប៍ខ្មែរ - សន្និសីទធ្វើនៅសាលាជាតិខាងរដ្ឋបាល នៅថ្ងៃទី ១ មិថុនា ១៩៧៤ នៅភ្នំពេញ ។

31. L'organisation buddhique au Cambodge, n°4 , Série Cuture et Civilisation Khmères, Phnom Penh, 1963.

32. ឯកសារមហាបុរសខ្មែរ របស់លោក អេងសុត - លេខ ២២ - ភ្នំពេញ គ.ស. ១៩៦៩ ។

33. ឯកសារមហាបុរសខ្មែរ របស់លោក អេងសុត - លេខ ២៣ - ភ្នំពេញ គ.ស. ១៩៦៩ ។

34. ឯកសារមហាបុរសខ្មែរ របស់លោក អេងសុត - លេខ ៧ - ភ្នំពេញ គ.ស. ១៩៦៩ ។

35. Madeleine Giteau, Depuis un siècle, un effort soutenu pour dégager et restaures Angkor, dans SOS Angkor, Courrier de L'Unesco, Décembre 1961.

36. ប្រជុំពង្សាវតារ ច្បាប់បណ្ណាល័យជាតិ- ក្បាលទី១ - រោងពុម្ពការហ្វា បោះពុម្ពលើកដំបូង - ក្បាលទី ១ ឧសភា ព.ស.២៥០៦ ( ជាភាសាថៃ) ។

37. Phan Khoang, Viêt Su : Xu Dang Trong 1558-1777, Saigon, 1969.

38. Lê Huong, Su Cac Miên, Saigon, 1970.

39. Charles Meyer, Phnom Penh, à la recherche du passé - les premiers occidenteaux à Phnom Penh, article publié dans Nokor Khmer, n°2, Phnom Penh, 1970.

40. Tran Trong Kim, Vietnam Su Luoc, Sagon, 1964.

41. G. Nandin, Histoire de la Cochinchine.

42. Jean Moura, Le Royaume du Cambodge, Paris, 1883.

43. ឯកសារមហាបុរសខ្មែរ របស់លោក អេងសុត - លេខ ៦៤ - ភ្នំពេញ គ.ស.១៩៦៩ ។

44. Adhémard Leclère, l'Histoire du Cambodge, Geuthner, Paris, 1914.

45. Lê Huong, Nguoi Viet gôc Miên, Sagon, 1969.

46. P. Schweisguth, un siècle d'histoire dans la péninsule indochinoise (1750-1850), Imprimerie Taupin et , Hanôi, 1944.

47. លោក កែវសុវត្ថិ - ចៅហ្វាយគុយ - ភ្នំពេញ - ១៩៧១ ។

48. Gérard Groussin,,Le protectorat Français sur le Cambodge de 1863 à 1884 (ronéotypé), Centre de documentation et de recherche de la Faculté des Lettres et des Sciences humaines de Phnom Penh, 1973.

49. Luang vichitr Vadakarn, Thailand's case, Bangkok, 1941.

50. Charles Meyer, Insurrections nationales du siècle dernier, dans Etudes cambodgiennes n° 9 , Phnom Penh, 1967.

51. M. Giteau, Histoire du Cambodge, Didier, Paris, 1957.

52. លោក ឌឹកគាម - អាចារ្យស្វា - ភ្នំពេញ គ.ស. ១៩៧៣ ។

53. La monarchie khmère, dans le Sangkum nº 5, décembre 1965, Phnom Penh.

54. L'histoire de Kralahom Kong par ImChhum (traduction libre Suon On et Charles Meyer), dans Etudes cambodgiennes nº 18, Phnom Penh, 1969.

55. Gaston Barrault, Cambodgiens de Cochinchine, Editions de la Revue Extrême - Orient, Saigon, 1927.

56. La frontière Khméro - vietnamienne, dans Etudes Cambodgiennes nº 7 Phnom Penh, 1966.

57. Sarin Chhak, Quelques faits historiques sur le tracé des frontières entre le Cambodge, le Laos et le Vietnam ចុះផ្សាយក្នុងទស្សនាវដ្ដីសាស្ត្រចារ្យ លេខ ១៤- ឆ្នាំទី ៥- ១៩៦៤ ។

58. La monarchie khmère, dans le Sangkum nº 6, Phnom Penh, 1966.

59. Ho Tong Peng, L'économie de l'hévéaculture en 1965, dans Etudes cambodgiennes nº 1, Phnom Penh, 1965.

60. លោក ឌឹកគាម និងលោក ឌៀកអំ - ភូមិគីរិថ្លាន - ភ្នំពេញ -គ.ស. ១៩៧១ ។

61. L'oeuvre de Sa Majesté Monivong, dans le Sangkum nº 8 Phnon Penh, 1966.